ជំនួយស្មារតី

# សន្ធានុក្រមសទិសន័យ

សាស្ត្រាចារ្យ ទូច-តីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៤

ជំនួយស្មារតី

# សទ្ទានុក្រមសទិសន័យ

សាស្ត្រាចារ្យ ទូច-គីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៤

**សទ្ទានុក្រមសទិសន័យ**

ឧបត្ថម្ភបោះពុម្ព : **សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**

ឧបត្ថម្ភផ្តែកគំនិត : **ឯកឧត្តម ហ៊ុន ហេង ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

រៀបរៀង : លោក **ទូច-គីមស្រ៊ាង** បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ

ជំនួយការ : លោក **អ៊ុន-សុភា** បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ

ឧត្តមទីប្រឹក្សា : ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ
: ឯកឧត្តម នាយឧត្តមសេនីយ៍ **តេង-សាវង្ស**
: ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ម-សំ**
: ឯកឧត្តម ឧត្តមសេនីយ៍ទោ **អឿ-សាវ៉ន**

ពិនិត្យអក្ខរាវិរុទ្ធ : ព្រះមហា **វ៉ែន-វិបុល** : លោក **អៀង-ពិសី**
: កញ្ញា **ផៃ-សាអ៊ែម** : កញ្ញា **ចាន់-នីតា**
: កញ្ញា **ឆិញ-ធីណា** : លោក **ទោត-ច័ន្ទវិបុល**
: លោក **វ៉ាន់-ផល្លី** : លោក **ប៊ុត-សុផល**

រចនាក្រប : កញ្ញា **នូ-ស៊ីនួន** រោងពុម្ព JSRC Printing House

ISBN-13 978-99963-705-0-2

រក្សាសិទ្ធិគ្រប់យ៉ាង ©


បោះពុម្ពលើកទី១ : ១១កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

អាសយដ្ឋានចែកចាយ : បណ្ណាល័យ សកលវិទ្យាល័យ វិទ្យាល័យ អនុវិទ្យាល័យ...

# អារម្ភកថា

សៀវភៅ សទ្ទានុក្រមសទិសន័យ នេះដែលព្រះតេជព្រះគុណ សម្តេច ទ្រង់ ឯកឧត្តម ឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ប្រិយមិត្តកំពុងតែអាន ខ្ញុំបានប្រើពេលវេលាយ៉ាងយូរក្នុងការរៀបរៀងសៀវភៅនេះឡើងក្នុងគោលបំណងបំពេញសំណូមពរលោកគ្រូ អ្នកគ្រូ និស្សិត អ្នកសិក្សាស្រាវជ្រាវដែលតែងតែចង់បានគោលគំនិតល្អៗនិងពង្រីកចំណេះដឹងបន្ថែមទៀតពី សទ្ទានុក្រមសទិសន័យ។

ការប្រមូលស្នាដៃរបស់អ្នកនិពន្ធទាំងឡាយតាំងពីអតីតកាល មករៀបរៀងជាសៀវភៅនេះឡើង គឺមានគោលបំណង គោលដៅ វិសាលភាព និយមន័យ បទពិសោធ ទស្សនៈបុរាណ ទស្សនៈថ្មីៗ ដើម្បីចូលរួមចំណែកអភិរក្សនិងអភិវឌ្ឍវិស័យភាសាខ្មែរយើង។

ក្នុងការសិក្សាកន្លងទៅគេបានកំណត់ថា **ភាសា អក្សរសាស្ត្រ** ជាមែកធាងសំខាន់ជាងគេនៃវប្បធម៌ ជាមេនៃប្រាជ្ញា ជាមេនៃការសិក្សា ជាមេនៃសិល្បៈ និងជាអត្តសញ្ញាណជាតិយ៉ាងសំខាន់បំផុត។

ប្រសិនបើមានកំហុសឆ្គងខ្លឹមសារដោយប្រការណាមួយ សូមអ្នកសិក្សាមេត្តាអធ្យាស្រ័យផងចុះ។ ខ្ញុំរង់ចាំទទួលយកកំហុសឆ្គងដោយសុឆន្ទៈ មនសិការសោមនស្សគំនិតកែលម្អពីសំណាក់លោកអ្នកសិក្សាស្រាវជ្រាវទាំងឡាយ។

រាជធានីភ្នំពេញ ១១កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី៤ ខែកញ្ញា គ.ស. ២០១៤

សាស្ត្រាចារ្យ **ឡុច-គីមស្រ៊ាង**

## **កតញ្ញូកតវេទិតាធម៌**

កូនសូមក្រាបថ្វាយបង្គំលើកហត្ថាប្រណម្យឧទ្ទិសស្នាដៃនេះ ជូនចំពោះលោកឪពុក **ទី-យ៉េន** និងអ្នកម្តាយ **អ៊ី-មាស** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃជីវិតកូន។

កូនសូមសម្តែងនូវកតញ្ញូកតវេទិតាធម៌ ជាអនេកប្បការចំពោះលោកមានគុណទាំងទ្វេ ដែលបានផ្តល់កំណើតដល់រូបកូននិងបានចិញ្ចឹមបីបាច់ថែរក្សាការពារអប់រំរូបកូនឱ្យឃ្លាតចាកឆ្ងាយពីអវិជ្ជា។ ព្រះគុណដ៏មហាប្រសើរនេះរូបកូនចងចាំអស់មួយជីវិតហើយមិនអាចរកអ្វីយកមកតបស្នងសងគុណឱ្យស្មើបានឡើយ។

សៀវភៅដែលកូនបានរៀបរៀងនេះគ្រាន់តែជាស្នាដៃតូចមួយប៉ុណ្ណោះ តែវាជាសក្ខីភាពមួយបញ្ជាក់ថា រូបកូនមិនបណ្តោយពេលវេលាឱ្យកន្លងផុតទៅដោយឥតប្រយោជន៍នោះទេ ហើយក៏មិនប្រើពេលវេលាដើម្បីប្រព្រឹត្តអំពើមិនគួរគប្បីណាមួយនោះដែរ។

កូនសូមគោរពសច្ចាប្រណិធានប្រព្រឹត្តតែកុសលកម្មនិងរស់នៅជាពលរដ្ឋល្អក្នុងសង្គមជាតិជារៀងរហូត។

រាជធានីភ្នំពេញ ១១កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី៤ ខែកញ្ញា គ.ស. ២០១៤

សាស្ត្រាចារ្យ **ខូច-គីមស្រ៊ាង**

## ឧទ្ទិសកថា

សូមខួទ្ទិសស្នាដៃនេះគោរពថ្វាយ ប្រគេន ជូនចំពោះ

❖ បុព្វបុរសខ្មែរស្នេហាជាតិដែលបានធ្វើពលិកម្មគ្រប់យ៉ាងការពារជាតិមាតុភូមិ

❖ អ្នកប្រាជ្ញ បណ្ឌិត កវី អ្នកនិពន្ធខ្មែរគ្រប់ជំនាន់ដែលបានខិតខំថែរក្សា ការពារវប្បធម៌ ភាសា អក្សរសាស្ត្រជាតិឱ្យបានរីកចម្រើនគង់វង្សរហូតមក

❖ សម្តេចព្រះមហាសុមេធាធិបតី **ជួន-ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ នៃគណៈមហានិកាយ ដែលព្រះអង្គបានបន្សល់ទុកស្នាព្រះហស្តដ៏ពិសេសសម្រាប់ខ្មែរគ្រប់ជំនាន់គឺ **វចនានុក្រមខ្មែរ**

❖ **អ្នកឧកញ៉ាមហាភក្តីសប្បុរិសភោគាធិបតី ហ៊ុន-នាង និងមហាឧបាសិកា ឌី-ប៉ុក**

❖ បុព្វការីជនរបស់ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទទាំងអស់

សូមជួយទ្រទ្រង់វិស័យវប្បធម៌ អក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ច។

រាជធានីភ្នំពេញ ១១កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី៤ ខែកញ្ញា គ.ស. ២០១៤

សាស្ត្រាចារ្យ **ខួច-គីមស្រ៊ាង**

# សេចក្តីថ្លែងអំណរគុណ

សូមគោរពសម្តែងការកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ដែលមានទឹកចិត្តសប្បុរិសធម៌ឧបត្ថម្ភធម្មទានថវិកាបំពេញបញ្ញាបារមីបោះពុម្ព សទ្ទានុក្រមសទិសន័យ ក្នុងគោលដៅផ្សព្វផ្សាយអក្សរសាស្ត្រខ្មែរ ដើម្បីឱ្យប្រជាពលរដ្ឋទូទៅបានយល់ដឹងពីគុណតម្លៃនៃផលប្រយោជន៍វប្បធម៌អក្សរសាស្ត្រជាតិ។

ក្នុងនាមអ្នកសិក្សាប្រាកដជាបំភ្លេចពុំបានចំពោះគុណូបការៈដ៏ធំធេងរបស់ **សម្តេច** ដែលបានរំដោះជាតិមាតុភូមិឱ្យផុតពីរបបអមនុស្សធម៌និងបង្រួបបង្រួមជាតិធ្វើឱ្យប្រទេសបានឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹតវឌ្ឍនភាពសង្គម ធ្វើឱ្យមានកិត្យានុភាពល្បីរន្ទឺទាំងនៅក្នុងតំបន់និងពិភពលោក។

គុណបំណាច់ដ៏សែនធំធេងនេះ បានជិតជាប់នៅក្នុងក្រអៅបេះដូងកូនខ្មែរដែលមានបុណ្យភ័ព្វវាសនាល្អ រស់នៅក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនៃ **សម្តេច** និងជាឱកាសដ៏ល្អដល់សមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរក្នុងការបំពេញបេសកកម្មអក្សរសាស្ត្រជាតិជូនដល់ប្រជាជនកម្ពុជាយើង។

សូម **សម្តេចតេជោបណ្ឌិតសភាចារ្យនិងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលការគោរពនិងការដឹងគុណដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

រាជធានីភ្នំពេញ ១១កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី៤ ខែកញ្ញា គ.ស. ២០១៤

# មាតិកានុក្រម

**ឈ្មោះមាតិកា** **ទំព័រ**

១-  អំពី កតកាសញ្ញា កិច្ចព្រមព្រៀងអន្តរជាត សន្ធិសញ្ញា..........១

២- អំពី កថាខណ្ឌ វាក្យខណ្ឌ..........................................២

៣- អំពី កម្មករ និយោជិត..............................................២

៤- អំពី កម្មវត្ថុ របៀបវារៈ............................................៣

៥- អំពី ករណីយកិច្ច កាតព្វកិច្ច ភារកិច្ច..........................៣

៦- អំពី កាព្យ កំណាព្យ...................................................៤

៧- អំពី កុបកម្ម កូដកម្ម ឃាតុកម្ម...................................៤

៨- អំពី កុសល បុណ្យ......................................................៦

៩- អំពី កេតនភណ្ឌ  បេតកភណ្ឌ......................................៧

១០- អំពី កំលុង ក្នុង អំឡុង.............................................៧

១១- អំពី ខ្លៅ ឆោត ល្ងង់..................................................៨

១២- អំពី គណៈកម្មការ គណៈកម្មាធិការ..........................៩

១៣- អំពី គណនី គណនេយ្យ............................................៩

១៤- អំពី ភាគទាន វិភាគទាន.........................................៩

១៥- អំពី គិត គំនិត ចិត្ត ញាណ វិញ្ញាណ អារម្មណ៍............១០

១៦- អំពី គុណធម៌ សីលធម៌ សុជីវធម៌..........................១៣

១៧- អំពី គុណសម្បត្តិ លក្ខណសម្បត្តិ..............................១៤

១៨- អំពី គោលការ គោលការណ៍.....................................១៤

១៩- អំពី គោលដៅ គោលបំណង........................................១៤
២០- អំពី គ្រប់គ្រង ដឹកនាំ................................................១៥
២១- អំពី គ្រូ សាស្ត្រាចារ្យ................................................១៥
២២- អំពី ងារ ឋានៈ ឋានន្តរ ឋានន្តរសក្តិ តំណែង ទី នាទី.........១៦
២៣- អំពី ចក្ខុវិស័យ ទស្សនវិស័យ......................................១៩
២៤- អំពី ចត ចំណត សំចត................................................១៩
២៥- អំពី ចរិត មារយាទ ឫក ឫកពា.....................................២០
២៦- អំពី ចេរភាព និរន្តរភាព..............................................២១
២៧- អំពី ចែករលែក ចែករំលែក..........................................២១
២៨- អំពី ចេះ ចាំ ជ្រាប ដឹង យល់ ស្គាល់............................២១
២៩- អំពី ចំណេះ វិជ្ជា........................................................២៤
៣០- អំពី ច្បាប់ នីត វិន័យ...................................................២៥
៣១- អំពី ជជែក ប្រឹក្សា ពិគ្រោះ ពិភាក្សា.............................២៦
៣២- អំពី ជញ្ជីង សញ្ជីង......................................................២៧
៣៣- អំពី ជាមួយ ជាមួយនឹង និង នឹង ព្រមទាំង មួយអន្លើដោយ
ហ្នឹង...............................................................................២៨
៣៤- អំពី ជាវ ទិញ លក់.......................................................៣០
៣៥- អំពី ជំនាញ ឯកទេស....................................................៣២
៣៦- អំពី ជំពូក ប្រការ ផ្នែក មាតិកា មាត្រា...........................៣២
៣៧- អំពី ឈ្លាប់ ធ្លាក់.........................................................៣៤

៣៨- អំពី ដង្ហែ ហែ.........................................................៣៤

៣៩- អំពី ដែរ ផង...........................................................៣៦

៤០- អំពី ដំណាច់ បំណាច់...................................................៣៦

៤១- អំពី ដំណឹង ព័ត៌មាន...................................................៣៧

៤២- អំពី ដំណើរការ ដំណើរការណ៍........................................៣៨

៤៣- អំពី តែ ប៉ុន្តែ............................................................៣៨

៤៤- អំពី តម្លៃ ថ្លៃ...........................................................៣៩

៤៥- អំពី ទំនឹម ភាសិត សុភាសិត ស្លោក..................................៤០

៤៦- អំពី ទម្លាប់ ទំនៀម ប្រពៃណី.........................................៤១

៤៧- អំពី ទ្រព្យ សម្បត្តិ.....................................................៤២

៤៨- អំពី និបាតសព្ទ អាយតនិបាត.........................................៤៣

៤៩- អំពី និព្វាន បរិនិព្វាន.................................................៤៤

៥០- អំពី និស្ស័យ ឧបនិស្ស័យ.............................................៤៥

៥១- អំពី និស្សិត សិក្ខាកាម សិស្ស........................................៤៦

៥២- អំពី នីតជន នីតបុគ្គល.................................................៤៧

៥៣- អំពី បង្រៀន បង្ហាត់....................................................៤៨

៥៤- អំពី បម្រាប បម្រាប់....................................................៤៨

៥៥- អំពី បរិយាយ អធិប្បាយ...............................................៤៩

៥៦- អំពី បាឋកថា សន្ទថា សុន្ទរកថា.....................................៤៩

៥៧- អំពី បុគ្គលិក សហការី សហសេវិក...................................៥០

៥៨- អំពី បុព្វកថា អារម្ភកថា....................................................៥១

៥៩- អំពី បុព្វហេតុ មូលហេតុ....................................................៥១

៦០- អំពី បេសកកម្ម បេសិតកម្ម..........................................................៥១

៦១- អំពី បេសកជន បេសិតជន..........................................................៥១

៦២- អំពី ប្រជុំ សន្និបាត សន្និសីទ សមាជ សិក្ខាសាលា.............៥២

៦៣- អំពី ប្រាប ប្រាប់..........................................................................៥៣

៦៤- អំពី ផ្លាក ស្លាក..........................................................................៥៤

៦៥- អំពី ពន្លត់ រលត់ រំលត់..................................................................៥៦

៦៦- អំពី ពី អំពី..................................................................................៥៧

៦៧- អំពី ពុទ្ធដីកា សច្ចដីកា....................................................................៥៨

៦៨- អំពី ព្រលឹង អត្ត អាត្មា....................................................................៥៩

៦៩- អំពី មោឃកភាព មោឃនភាព..........................................................៦០

៧០- អំពី យល់ព្រម ឯកភាព....................................................................៦១

៧១- អំពី យស សក្តិ..................................................................................៦២

៧២- អំពី រលែក រំលែក..........................................................................៦៣

៧៣- អំពី រូបិយបណ្ណ រូបិយវត្ថុ............................................................៦៣

៧៤- អំពី លទ្ធភាព សមត្ថភាព................................................................៦៣

៧៥- អំពី លទ្ធិ សាសនា..........................................................................៦៤

៧៦- អំពី វរៈ វីរៈ.....................................................................................៦៥

៧៧- អំពី វាសនា សំណាង.........................................................................៦៦

# *សទ្ទានុក្រមសទិសន័យ*

## អំពី កតិកាសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ សន្ធិសញ្ញា

**កតិកាសញ្ញា** *ន.* (បា.) សញ្ញា គឺការសន្មតគ្នា, ការមត់គ្នាទុកជាគ្រឿងសម្គាល់ :

❖ យើងត្រូវធ្វើកតិកាសញ្ញាមួយ។

☞ ***អត្ថន័យម្យ៉ាងទៀត៧*** : កិច្ចព្រមព្រៀងមួយដែលត្រូវបានធ្វើឡើងរវាងភាគីពីរឬច្រើនឬក៏រវាងរដ្ឋនិងរដ្ឋ ទាំងផ្លូវការ ទាំងមិនផ្លូវការ ដើម្បីធ្វើអ្វីមួយរួមគ្នាក្នុងគោលបំណងបម្រើផលប្រយោជន៍រវាងគ្នាទៅវិញទៅមក។

**កិច្ចព្រមព្រៀងអន្តរជាតិ** *ន.* មានន័យដូច សន្ធិសញ្ញា ដែរ ប៉ុន្តែមានលក្ខណៈផ្លូវការតិចជាង សន្ធិសញ្ញា។ លក្ខណវិនិច្ឆ័យនៃកិច្ចព្រមព្រៀង :

❖ ត្រូវបានប្រើជាពិសេសសម្រាប់លិខិតូបករណ៍ ដែលមានលក្ខណៈបច្ចេកទេសឬរដ្ឋបាល

❖ កិច្ចព្រមព្រៀងមិនទាមទារឱ្យមានការផ្លាស់សច្ចាប័នពីសភាឡើយ

❖ ករណីខ្លះកិច្ចព្រមព្រៀងអាចមិនមានទម្រង់ជាលាយលក្ខណ៍អក្សរដូចជាកិច្ចព្រមព្រៀងផ្ទាល់មាត់អាចជាកិច្ចសន្យាដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីការបរទេសនៃប្រទេសមួយជាមួយនឹងដៃគូរបស់ខ្លួន ឬជាមួយនឹងរដ្ឋដទៃទៀត។

***ឧ.*** កិច្ចព្រមព្រៀងទូទៅស្ដីពីពាណិជ្ជកម្មនិងពន្ធគយ។

**សន្និសញ្ញា** *ន.* (បា.) ការសន្យាគ្នា, ការសន្យាជាមេត្រីនឹងគ្នា, សំបុត្រសន្យាគ្នាទៅវិញទៅមក...។

## អំពី **កថាខណ្ឌ វាក្យខណ្ឌ**

**កថាខណ្ឌ** *ន.* (បា. សំ.) សង្កាត់នៃពាក្យ, សង្កាត់នៃសម្ដី, សង្កាត់នៃ ពំនោល, សង្កាត់នៃការសម្ដែង, សង្កាត់នៃរឿង, ផ្នែកនៃពាក្យ, ផ្នែកនៃសម្ដី, ផ្នែកនៃពំនោល, ផ្នែកនៃការសម្ដែង, ផ្នែកនៃរឿង, ប៉ែកនៃពាក្យ, ប៉ែកនៃសម្ដី, ប៉ែកនៃពំនោល, ប៉ែកនៃការសម្ដែង, ប៉ែកនៃរឿង។

❀ កថាខណ្ឌ កើតឡើងដោយការផ្សំល្បះជាច្រើនដែលមានគោលគំនិតដូចគ្នា។ មួយកថាខណ្ឌ គឺមួយគំនិតចម្បង។

☞ ***អត្ថន័យម្យ៉ាងទៀតថា*** : សង្កាត់នៃសេចក្ដី, វគ្គ, ប៉ែកនៃកថា, ចំណែកនីមួយៗនៃមាត្រា។

❖ មាត្រា១១នៃច្បាប់ចរាចរណ៍ផ្លូវគោក ឆ្នាំ១៩៩១ មានពាកថាខណ្ឌ, កថាខណ្ឌទី១ មាន៦វគ្គ។

**វាក្យខណ្ឌ** *ន.* (បា. សំ.) សង្កាត់របស់ពាក្យ។

❖ ក្នុងប្រយោគនេះមានពីរវាក្យខណ្ឌ។

## អំពី **កម្មករ និយោជិត**

**កម្មករ** *ន.* (បា.) អ្នកធ្វើការបម្រើដោយឈ្នួល (អ្នកស៊ីឈ្នួល) :

❖ ពួកកម្មករកំពុងធ្វើការខ្សៀវ។

**និយោជិត** *ន.* (បា.) អ្នកដែលគេប្រើឱ្យធ្វើការ, កូនឈ្នួល, ភ្នាក់ងារដែលធ្វើការក្រោមបង្គាប់ចៅហ្វាយនាយក្នុងគ្រឹះស្ថានឯកជនឬក្នុងក្រសួងរាជការ :

❖ ក្នុងរោងចក្រធ្វើក្រដាសនេះ មាននិយោជិតចំនួន៤០០នាក់។

## អំពី **កម្មវត្ថុ របៀបវារៈ**

**កម្មវត្ថុ** *ន.* (បា.) រឿងនៃការងារ, សេចក្ដីបំប្រួញរឿងក្នុងសំបុត្រស្នាមផ្សេងៗដើម្បីឱ្យដឹងថាជារឿងនេះ រឿងនោះ :

❖ សំបុត្រជាផ្លូវការច្រើនតែមានកម្មវត្ថុ។

**របៀបវារៈ** *ន.* បញ្ហាទាំងឡាយដែលដាក់ជូនអង្គសន្និបាតឬអង្គប្រជុំដើម្បីពិភាក្សាដោះស្រាយ, បញ្ហាទាំងឡាយដែលចុះក្នុងកម្មវិធីនៃអង្គសន្និបាតឬអង្គប្រជុំអ្វីមួយ។

## អំពី **ករណីយកិច្ច កាតព្វកិច្ច ភារកិច្ច**

**ករណីយកិច្ច** *ន.* (បា.) កិច្ចដែលគួរធ្វើ, ការងារដែលត្រូវតែធ្វើ :

❖ មុខការនេះជាករណីយកិច្ចរបស់អ្នកហើយ។

**កាតព្វកិច្ច** *ន.* (បា.) កិច្ចដែលគួរធ្វើ, ការងារដែលត្រូវតែធ្វើ, ករណីយកិច្ច។

🕯 ខ្មែរច្រើនតែប្រើសំដៅ **កាតព្វកិច្ច** សង្កត់ធ្ងន់ជាង **ករណីយកិច្ច** ទៅវិញ។

**ភារកិច្ច** *ន.* (បា.) កិច្ចជាភារៈ, កិច្ចជាទម្ងន់, កិច្ចជាបន្ទុក, កិច្ចការធ្ងន់។

## អំពី ភាព្យ កំណាព្យ

**ភាព្យ** *ន.* (បា.) របៀបពាក្យច្ចួនមានឃ្លោងឃ្លា (***កំណាព្យ***) :

- ❖ ពាក្យកាព្យ
- ❖ តែងកាព្យ។

**កំណាព្យ** *ន.* ពាក្យកាព្យ :

- ❖ លើកកំណាព្យ
- ❖ តែងកំណាព្យ។

## អំពី កុបកម្ម កូដកម្ម បាតុកម្ម

**កុបកម្ម** *ន.* (បា.) អំពើជ្រួលជ្រើម, ការបះបោរ, ចលាចល។

☞ ***អត្ថន័យម្យ៉ាងទៀត៖*** : ការបះបោរឬចលាចលដោយប្រើអំពើហិង្សាបង្កឡើងដោយមនុស្សមួយក្រុមឬច្រើនក្រុម នៅពេលពួកគេមិនពេញចិត្តទៅលើបញ្ហាណាមួយ។ **កុបកម្ម** អាចកើតចេញពី កូដកម្ម ឬ បាតុកម្ម នៅពេលដែល កូដករ ឬ បាតុករ ចាប់ផ្តើមប្រែក្លាយការតវ៉ាឬទាមទារដោយសន្តិវិធីទៅជាការតវ៉ាឬទាមទារដោយប្រើអំពើហិង្សា។

❖ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ កុបករបាននាំគ្នាធ្វើកុបកម្មវាយបំផ្លាញស្ថានទូតថៃ។

**កុដកម្ម ន.** (ឆា.) អំពើព្រហើន, អំពើកោងកាចរៀចវេរ, អំពើពុតត្បុត, ការសម្ដែងអាកប្បកិរិយាប្រឆាំងចំពោះរឿងឬកិច្ចការណាមួយ ដែលខ្លួនមិនពេញចិត្ត។

☞ ***អត្ថន័យម្យ៉ាងទៀត៣*** : ការសម្ដែងអាកប្បកិរិយាប្រឆាំងចំពោះរឿងឬកិច្ចការណាមួយដែលខ្លួនមិនពេញចិត្ត តាមរយៈការមិនចូលរួមបំពេញភារកិច្ចអ្វីមួយ ការមិនចូលធ្វើការ ការដាក់ទណ្ឌកម្មខ្លួនឯងហើយក្នុងករណីខ្លះអាចឈានទៅរកការធ្វើអត្តឃាត។

**បាតុកម្ម ន.** (ឆា.) អំពើដាក់ស្ដែង, ការធ្វើឱ្យដឹងប្រាកដ, ការធ្វើឱ្យឃើញប្រាកដ, ការលើកគ្នាដើរដង្ហែជាក្បួន ដើម្បីសម្ដែងសេចក្ដីមិនពេញចិត្តចំពោះអំពើអ្វីមួយឬទទូចសុំស្រុះគ្នា ឱ្យសម្រេចផលប្រយោជន៍អ្វីមួយតាមសេចក្ដីពេញចិត្តខ្លួនទាំងអស់គ្នា :

- ❖ បាតុកម្មនៃពួកកម្មករ...
- ❖ ធ្វើបាតុកម្មសម្ដែងការណ៍មិនពេញចិត្តចំពោះរឿង...។
- ✈ បាតុកម្មបំពានច្បាប់ : បាតុកម្មខុសផ្លូវច្បាប់
- ✈ បាតុកម្មឡើងចាង : បាតុកម្មតាមទំនើងក្រៅលក្ខណានុញ្ញាត
- ✈ បាតុកម្មសុភាព : បាតុកម្មសុភាពរាបសាតាមលក្ខណានុញ្ញាត...។

☞ ***អត្ថន័យម្យ៉ាងទៀត៣*** : អំពើដាក់ស្ដែង ការធ្វើឱ្យដឹងឬឱ្យឃើញប្រាកដការលើកគ្នាដើរដង្ហែជាក្បួន ដើម្បីសម្ដែងសេចក្ដីមិនពេញចិត្តចំពោះ

អំពើអ្វីមួយ ឬទទូចសុំស្រុះគ្នាឱ្យសម្រេចផលប្រយោជន៍អ្វីមួយតាមសេចក្ដីពេញចិត្តរបស់ក្រុមខ្លួន។

## អំពី កុសល បុណ្យ

**កុសល** *ន.* (បា.) កម្មដែលកម្ចាត់បង់នូវអំពើអាក្រក់ (បុណ្យ)។

**កុសល** *គុ.* (បា.) ដែលល្អប្រពៃ, ដែលជាបុណ្យ :

❖ ចិត្តកុសល។

✍ ដែលប៉ិនប្រសប់ : កុសលបណ្ឌិត, ដែលឈ្លាសវាងវៃ។

✍ ដែលឈ្លាសវាងវៃ : កុសលបណ្ឌិត, ដែលប៉ិនប្រសប់។

**បុណ្យ** *ន.* (សំ.) គុណជាតជាគ្រឿងជម្រះសន្ដានចិត្ត, កុសល, អំពើល្អ, សេចក្ដីសុខ។

✍ ធ្វើបុណ្យ : ធ្វើសេចក្ដីល្អខាងផ្លូវកាយវាចាចិត្តឱ្យកើតមានដោយកិច្ចនិងទំនងផ្សេងៗ...។

✍ បុណ្យសក្ដិ : អំណាចតេជះបានដោយសារបុណ្យ (យសសក្ដិ ឬការងារ)។

✍ ឡើងបុណ្យ : ឡើងសក្ដិយសខ្ពស់ជាងមុន។

✍ ព្រះមានបុណ្យ : ព្រះភគវ័ត (ព្រះសម្មាសម្ពុទ្ធ)។

☞ ពាក្យថា **បុណ្យ** នេះខាងសំស្ក្រឹតប្រើជា *គុ.* ផងក៏បាន, ប្រែថា «**បរិសុទ្ធ, ស្អាត, ល្អ, គួរចង់បាន, គួរស្រលាញ់**»។

## អំពី កេតនភណ្ឌ បេតិកភណ្ឌ

**កេតនភណ្ឌ** *ន.* (បា.) របស់ដែលទុកដូចជាទង់សម្រាប់ជាតិឬសម្រាប់ប្រទេស, វត្ថុដ៏ឧត្តុង្គឧត្តម, និមិត្តរូប :

❖ ប្រទេសនីមួយៗលុះត្រាតែមានឯករាជ្យពេញបរិបូណ៌ដោយសេរីភាពគ្រប់យ៉ាងទើបឈ្មោះថាមានកេតនភណ្ឌ។

**បេតិកភណ្ឌ** *ន.* (បា.) ទ្រព្យសម្បត្តិឬកេរមត៌កមានជាប់តមកពីខាងឪពុក :

❖ ស្រែទាំងអស់នេះជាបេតិកភណ្ឌរបស់ខ្ញុំ។

## អំពី កំលុង ក្លុង អំឡុង

**កំលុង** *ន.* ទី, ពួក, ក្រុម, ក្រវល់ :

❖ នៅក្នុងកំលុងជាមួយគ្នា

❖ កំលុងដប់ឆ្នាំ

❖ កំលុងមួយរយឆ្នាំ

❖ កំលុងមួយពាន់ឆ្នាំ

❖ កំលុងមួយម៉ឺនឆ្នាំ។

**ក្លុង** *អា. និ.* កំលុង, រវាងមានលក្ខខណ្ឌ :

❖ ក្នុងផ្ទះ

❖ ក្នុងភូមិ

❖ ក្នុងស្រុក

❖ ក្នុងថ្ងៃនេះ

❖ ក្នុងឆ្នាំនេះ។

**អំឡុង** *ន.* កាលយូរ :

❖ ក្នុងអំឡុង១០ឆ្នាំ។

## អំពី ខ្លៅ ឆោត ល្ងង់

**ខ្លៅ** *គុ.* ដែលល្ងង់ព្រោះឥតចំណេះដោយមិនបានសិក្សារៀនសូត្រ :

❖ មនុស្សខ្លៅ។

**ឆោត** *គុ.* ដែលងាយបញ្ឆោត :

❖ គំនិតឆោត

❖ មនុស្សឆោត។

✎ ឆោតឆៅ *គុ.* ដែលឆោតខ្លៅឆៅគំនិត។

**ល្ងង់** *កិ.* មិនចេះ, មិនយល់ :

❖ ខ្ញុំល្ងង់គិតមិនលេច។

**ល្ងង់** *គុ.* ដែលមិនចេះ, ដែលមិនយល់ :

❖ មនុស្សល្ងង់។

✎ ល្ងង់ខ្លៅ : ល្ងង់ព្រោះឥតបានរៀនសោះ

✎ ងងឹតល្ងង់ : ល្ងង់ឈឹងសូន្យដូចគេនៅក្នុងទីងងឹត

✎ ឆោតល្ងង់ : ឆោតផងល្ងង់ផង

✎ ល្ងេល្ងង់ : ល្ងង់ល្ងេល្ងើពុំយល់ការខុសត្រូវ។

## អំពី គណៈកម្មការ គណៈកម្មាធិការ

**គណៈកម្មការ** *ន.* (ឆា.) ជនមួយក្រុមឬក្រុមជំនុំដែលចាត់តាំងឡើងដោយពិធីបោះឆ្នោត ឬដោយការជ្រើសតាំងសម្រាប់ឱ្យពិនិត្យកិច្ចការណាមួយដាច់មុខដោយឡែក :

- ❖ គណៈកម្មការវប្បធម៌បានបង្កើតពាក្យខ្មែរថ្មីៗជាច្រើន។

**គណៈកម្មាធិការ** *ន.* (ឆា.) សមាជិកមួយក្រុមដែលតាំងឡើងក្នុងក្រសួងរាជការឬសភាដើម្បីឱ្យប្រតិបត្តិសម្រេចការណាមួយ :

- ❖ មុខការនេះស្រេចលើគណៈកម្មាធិការ។

## អំពី គណនី គណនេយ្យ

**គណនី** *ន.* (ឆា.) ការរាប់, បញ្ជីឬតារាងគិតគូរប្រាក់ចំណូលចំណាយ។

**គណនេយ្យ** *ន.* (ឆា.) គណនីក្នុងក្រសួងរាជការឬក្នុងគ្រឹះស្ថានពាណិជ។

## អំពី ភាគទាន វិភាគទាន

**ភាគទាន** *ន.* (ឆា.) ចំនួនប្រាក់រៃអង្គាសដែលជនម្នាក់ៗចូលក្នុងកិច្ចការកុសលណាមួយ :

- ❖ ឃោសនាសុំឱ្យគេជួយចូលភាគទាន
- ❖ បង់ភាគទានប្រចាំខែចំនួន២ ០០០រៀល។

**វិភាគទាន** *ន.* (ឆា.) ការឱ្យនូវភាគផ្សេងៗ។ អំណោយដែលឥតកំណត់ចំនួន, ចំណែកដែលបុគ្គលម្នាក់ៗនាំយកមកចូលជាជំនួយក្នុងកិច្ចការណាមួយ :

❖ ធ្វើវិភាគទាន

❖ បានទទួលវិភាគទាន។

## អំពី គិត គំនិត ចិត្ត ញាណ វិញ្ញាណ អារម្មណ៍

**គិត** *កិ.* ត្រិះរិះ, ពិចារណា, នឹក, នឹកដល់, រឭក :

❖ គិតហើយសឹមធ្វើ។

**គំនិត** *ន.* ការគិត, យោបល់ :

❖ គំនិតល្អ

❖ គំនិតស្ដាំ

❖ គំនិតឆ្វេង

❖ គំនិតអាក្រក់។

✈ ទាល់គំនិត : ទាល់ផ្លូវ, អស់ផ្លូវ។

**ពាក្យទំនឹមបុរាណ**

**ប្រាំបួនទាល់ ដប់ទាល់ កុំឱ្យតែទាល់គំនិត។**

**ចិត្ត** *ន.* (**បា. សំ.**) ធម្មជាតសម្រាប់សន្សំអារម្មណ៍, ធម្មជាតសម្រាប់គិត គឺវិញ្ញាណ :

❖ ចិត្តល្អ

❖ ចិត្តត្រង់

❖ ចិត្តវៀច

❖ ចិត្តអាក្រក់...។

**ញាណ** *ន.* (**បា.**) សេចក្ដីដឹង, ប្រាជ្ញា... :

▦ **ទ្រង់ញាណ** (ព្រះពុទ្ធ) ទ្រង់ជ្រាបច្បាស់នូវកិច្ចការអាថ៌កំបាំងជ្រាលជ្រៅផ្សេងៗដោយព្រះប្រាជ្ញា; គេតែងប្រើពាក្យ ទ្រង់ញាណ នេះក្នុងការស្ដីបន្ទោសគ្នីគ្នាថា :

❖ គ្មាននរណាទ្រង់ញាណដូចព្រះទេ

❖ បើខ្លួនមិនប្រាប់ធ្វើម្ដេចឱ្យគេដឹងផងបាន?

**វិញ្ញាណ** *ន.* (**បា.**) ធម្មជាតដឹងច្បាស់នូវអារម្មណ៍ (ចិត្ត) :

❖ ភ័យស្លុតខ្លាំងស្ទើរបាត់វិញ្ញាណ។

- ឬាត់វិញ្ញាណ : រលត់វិញ្ញាណ
- រលត់វិញ្ញាណ : រលត់វិញ្ញាណ, បាត់វិញ្ញាណ។

**អារម្មណ៍** *ន.* (**បា. អារម្មណ**) គ្រឿងតោង, គ្រឿងព្យួរ, គ្រឿងទាញឬទាក់ទាញ, គ្រឿងតោងរបស់ចិត្ត, គំនិត, ការដឹង, ...។ ដែលប្រើដោយច្រើន, សំដៅត្រង់ គ្រឿងតោងរបស់ចិត្ត មាន៦ប្រភេទ :

- រូបារម្មណ៍ (សម្រាប់ភ្នែក)
- សទ្ទារម្មណ៍ (សម្រាប់ត្រចៀក)
- គន្ធារម្មណ៍ (សម្រាប់ច្រមុះ)
- រសារម្មណ៍ (សម្រាប់អណ្ដាត)

- ផោដ្ឋព្វារម្មណ៍ (សម្រាប់សព៌ាង្គកាយ លើកអាយតនៈ៥ចេញ)
- ធម្មារម្មណ៍ (សម្រាប់ចិត្តសុទ្ធ) :
  - អារម្មណ៍ល្អ
  - អារម្មណ៍មិនល្អ
  - អារម្មណ៍មិនទៀង។

សំដៅត្រង់ **គំនិត** និង **ការដឹង**, ដូចជា :

- កៀងអារម្មណ៍ : កៀងប្រមូលគំនិតមិនឱ្យទាសរសេមរសាម
- ឃ្វាងអារម្មណ៍ : ឃ្វាងគំនិត
- ចាប់អារម្មណ៍ : ចាប់ចិត្ត, ជាប់ចិត្ត, ជាប់គំនិត
- ជិះអារម្មណ៍ : ផ្ទួនគំនិត
- ជោកអារម្មណ៍ : ជោកគំនិត, ស៊ប់ចិត្តពេញទី
- ទទួលអារម្មណ៍ : ទទួលដឹង, បានដឹង (ដោយភ្នែកឃើញរូបជាដើម)។
- ទប់អារម្មណ៍ : ទប់គំនិត
- ទាញអារម្មណ៍ : ទាញគំនិត
- ទាសអារម្មណ៍ : ទាសគំនិត, គំនិតទាស
- អារម្មណ៍ទាស : ទាសគំនិត, គំនិតទាស, ទាសអារម្មណ៍
- ទាស់អារម្មណ៍ : ទាស់ចិត្ត, ទាស់អធ្យាស្រ័យ; មិនត្រូវធាតុគ្នា
- ប៉ះអារម្មណ៍ : ប៉ះរូបារម្មណ៍ជាដើម; ទង្គុកចិត្តគ្នា

- ប្រទះអារម្មណ៍ : ប្រទះរូបារម្មណ៍ជាដើម; ទង្គុកចិត្តគ្នា។
- ប្រមូលអារម្មណ៍ : ប្រមូលគំនិត, ធ្វើឱ្យមូលចិត្ត។
- រងអារម្មណ៍ : ទទួលអារម្មណ៍, ចាប់អារម្មណ៍។
- សោយអារម្មណ៍ : ទទួលអារម្មណ៍, ចាប់អារម្មណ៍, រងអារម្មណ៍។
- ស្ទាក់អារម្មណ៍ : ស្ទាក់ផ្លូវគំនិត។

**អំពី គុណធម៌ សីលធម៌ សុជីវធម៌**

**គុណធម៌** *ន.* ធម៌ដែលមានដំណើរចម្រើនសេចក្ដីសុខទុក្ខតាមជាន់តាមថ្នាក់បានខាងអំពើល្អអាក្រក់ គឺបុណ្យបាបដែលបុគ្គលធ្វើ។ សេចក្ដីល្អ, សេចក្ដីបរិសុទ្ធ, សេចក្ដីអាណិត, សេចក្ដីប្រណី...ៗ

**សីលធម៌** *ន.* សីលដែលជាធម៌ (របស់សត្វលោក), សីលនិងធម៌, កិរិយាមារយាទ, សណ្ដាប់ធ្នាប់, ដំបូន្មាន ដែលនាំឱ្យចៀសវាងអំពើអាក្រក់ហើយឱ្យប្រព្រឹត្តតែអំពើល្អ :

- ប្រកបដោយសីលធម៌
- ប្រាសចាកសីលធម៌។

**សុជីវធម៌** *ន.* (**សំ.**) ការរស់នៅដោយល្អ គឺចំណេះ, សណ្ដាប់ធ្នាប់, ការដឹងប្រមាណគួរសមក្នុងកិច្ចការប្រាស្រ័យជាមួយនឹងអ្នកដទៃ :

- មានសុជីវធម៌
- មនុស្សខ្វះសុជីវធម៌។

## អំពី គុណសម្បត្តិ លក្ខណសម្បត្តិ

**គុណសម្បត្តិ** *ន.* សេចក្ដីដល់ព្រមដោយគុណ គឺការបរិបូណ៌ដោយសេចក្ដីល្អ, សេចក្ដីបរិសុទ្ធ :

❖ មនុស្សនេះមានគុណសម្បត្តិគួរឱ្យសរសើរ។

**លក្ខណសម្បត្ត** *ន.* ការដល់ព្រមដោយលក្ខណៈ, ការដល់ព្រមដោយគ្រឿងសម្គាល់, ការពេញលេញដោយគ្រឿងចំណាំ, ការដល់ព្រមដោយគុណសម្បត្តិ។

## អំពី គោលការ គោលការណ៍

**គោលការ** *ន.* ផែនការដែលត្រូវធ្វើ, គម្រោងការដែលត្រូវធ្វើ :

❖ ធ្វើតាមគោលការ

❖ គោលការ៥ឆ្នាំ។

**គោលការណ៍** *ន.* ហេតុការណ៍ជាគោល, ហេតុដែលមានសារៈសំខាន់ :

❖ រឿងនេះគ្រាន់តែជាគោលការណ៍ទេ

❖ បុគ្គលនេះមានតែគោលការណ៍ តែមិនទាន់មានការប្រតិបត្តិឬការពិសោធនៅឡើយទេ

❖ គោលការណ៍ទុកជាមូលដ្ឋាននៃកិច្ចប្រតិបត្តិ។

## អំពី គោលដៅ គោលបំណង

**គោលដៅ** *ន.* លទ្ធផលចុងបញ្ចប់ដែលមនុស្សឬគម្រោងណាមួយចង់ធ្វើឱ្យបានសម្រេច។

**គោលបំណង** *ន.* បំណងគោល, បំណងសំខាន់, បំណងជាអាទិភាព។

## អំពី គ្រប់គ្រង ដឹកនាំ

**គ្រប់គ្រង** *កិ.* បីបាច់, រក្សា, ថែទាំដោយទទួលរងបន្ទុកលើខ្លួន, ថែទាំដោយទទួលរងខុសត្រូវលើខ្លួន។

**ដឹកនាំ** *កិ.* ណែនាំ, ប្រាប់ទំនងឱ្យយល់ឱ្យភ្លឺ, ប្រាប់ឧបាយឱ្យយល់ឱ្យភ្លឺ, នាំឱ្យធ្វើដោយពន្យល់បណ្ដើរ :

❖ បណ្ឌិតតែងដឹកនាំអ្នកដទៃទៅកាន់សេចក្ដីសុខចម្រើន។

## ការគ្រប់គ្រងនិងការដឹកនាំ

| I- **អ្នកគ្រប់គ្រង** | II- **អ្នកដឹកនាំ** |
|---|---|
| ១- រក្សាស្ថានភាពឱ្យនៅដដែល | ១- ផ្លាស់ប្ដូរនិងកែប្រែ |
| ២- ត្រួតពិនិត្យ | ២- ផ្ដល់សេរីភាព |
| ៣- ផ្ដោតលើពេលកំណត់ | ៣- សម្លឹងឆ្ពោះទៅអនាគត |
| ៤- មិនបត់បែន | ៤- មានភាពបត់បែន |
| ៥- ផ្ដោតទៅលើកាលវិភាគការងារ | ៥- ផ្ដោតទៅលើគោលដៅ |
| ៦- ធ្វើការងារឱ្យត្រឹមត្រូវ។ | ៦- ធ្វើការងារដែលត្រឹមត្រូវ។ |

## អំពី គ្រូ សាស្ត្រាចារ្យ

**គ្រូ** *ន.* (បា. គរុ) អ្នកដែលមានចិត្តធ្ងន់, អ្នកដែលគួរគេគោរព គឺអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗដល់សិស្ស :

❖ គ្រូអក្សរ

❖ គ្រូលេខ

❖ គ្រូភ្លេង...។

**សមណៈដែលបំបួសកុលបុត្រឱ្យបានជាបព្វជិត** :

❖ គ្រូបំបួស

❖ គ្រូសូត្រ។

**ពេទ្យរក្សារោគ** :

❖ គ្រូពេទ្យ

❖ គ្រូថ្នាំ

❖ ទៅរកគ្រូមកមើលជំងឺ។

**សាស្ត្រាចារ្យ** *ន.* គ្រូបង្រៀនគម្ពីរ, គ្រូបង្រៀនគម្ពីរប្រាប់វិទ្យា, គ្រូបង្រៀនគម្ពីរសាសនា, គ្រូបង្រៀនច្បាប់, គ្រូបង្រៀនច្បាប់ប្រដៅ, គ្រូបង្រៀនក្បួន, គ្រូបង្រៀនតម្រា, គ្រូបង្រៀនវិជ្ជា, គ្រូបង្រៀនការសិក្សា, គ្រូបង្រៀនពាក្យណែនាំ, គ្រូបង្រៀនពាក្យពន្យល់, គ្រូបង្រៀនពាក្យបង្គាប់។

**អំពី ងារ ឋានៈ ឋានន្តរ ឋានន្តរសក្តិ តំណែង ឋី នាទី**

**ងារ** *ន.* មុខការ, ទីតំណែងរាជការតាមបណ្ដាសក្តិ, តាមក្រសួង, បណ្ដាសក្តិ, យសសក្តិ, ឋានន្តរ :

❖ លោកហ្នឹងមានងារជាអ្វី?

❖ លោកមានងារជាហ្លួងពិភក្តិអក្សរ។

**ដូចនេះអាចថា**

☞ ហ្លួងពិតក្តិអក្សរជា **ងារ**។

**ឋានៈ** *៩.* ងារ, មុខងារ, ថ្នាក់ងារ, ថ្នាក់សក្តិយស :

❖ លោកមានឋានៈជាអ្វី?

❖ លោកមានឋានៈជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច

❖ គួរកុំប្រកាន់ឋានៈពេក។

**ដូចនេះអាចថា**

➥ នាយករដ្ឋមន្ត្រី

➥ ឧបនាយករដ្ឋមន្ត្រី

➥ ទេសរដ្ឋមន្ត្រី

➥ រដ្ឋមន្ត្រី

➥ រដ្ឋលេខាធិការ

➥ អនុរដ្ឋលេខាធិការ...ជា **ឋានៈ**។

**ឋានន្តរ** *៩.* លំដាប់នៃទី, មុខងារ, ងារ, ថ្នាក់ងារ, ថ្នាក់សក្តិយស :

❖ លោកមានឋានន្តរជាអ្វី?

❖ លោកមានឋានន្តរជាអភិបាលស្រុក

❖ លោកមានឋានន្តរជាព្រះចម្រើនសម្បត្តិ។

**ដូចនេះអាចថា**

- ➥ អភិបាលរាជធានី
- ➥ អភិបាលក្រុង
- ➥ អភិបាលខេត្ត
- ➥ អភិបាលខណ្ឌ
- ➥ អភិបាលស្រុក
- ➥ នាយសង្កាត់
- ➥ មេឃុំ
- ➥ មេភូមិ...ជា **ឋានន្តរ**។

**ឋានន្តរសក្តិ** *ន.* អំណាចតាមមុខងារ, បណ្តាសក្តិធំតូចតាមមុខងារ :

- ❖ អង្គុយតាមឋានន្តរសក្តិ។

**តំណែង** *ន.* របៀបលំដាប់កិត្តិយសមន្ត្រី, មុខក្រសួង, មុខងារ, មុខការ :

- ❖ លាចាកមុខតំណែង
- ❖ ដាក់ឱ្យនៅក្រៅតំណែង។

**ទី** *ន.* ក្រសួង, មុខងារ :

- ❖ ទីសេនាបតី
- ❖ ស្តីទីចាងហ្វាង។

**ដូចនេះអាចថា**

↳ សេនាបតី

↳ ចាងហ្វាង...ជា **ឱ** ជា **មុខងារ**។

**នាទី** *ន.* មុខក្រសួង, មុខងារ, មុខការ :

❖ ធ្វើការតាមនាទីរបស់ខ្លួន

❖ ធ្វើតាមនាទីដែលគេដាក់ឱ្យ។

**អំពី ចក្ខុវិស័យ ទស្សនវិស័យ**

**ចក្ខុវិស័យ** *ន.* ទិដ្ឋភាពឬរូបភាពក្នុងអារម្មណ៍ពីអ្វីដែលគេចង់បានទៅអនាគតវែងឆ្ងាយ, ការអាចមើលឬស្រមៃឃើញអនាគតដែលអាចបាន។

**ទស្សនវិស័យ** *ន.* ទីឱកាសដែលមើលឃើញ គឺចម្ងាយដែលភ្នែកល្មមមើលឃើញបាន (ចម្ងាយមួយក្រឡេកឬមួយកន្ទុយភ្នែក)។

**អំពី ចត ចំណត សំចត**

**ចត** *កិ.* បញ្ឈប់នាវាផ្សេងៗ នៅផែ, ក្បូនជាដើមដោយចងពួរឬបោះយុថ្កា :

❖ ចតទូក

❖ ចតកប៉ាល់។

**ចំណត** *ន.* ដំណើរដែលចត, ទីសម្រាប់ចត :

❖ ចំណតទូក

❖ មួយចំណត

❖ ពីចំណាត (សំស្រ្កឹត **ស្ថានីយ**)។

**សំចត** *កិ.* ចតឈប់, ឈប់ត្រង់ទីចត, ឈប់សំណាក់, ឈប់សម្រាកក្នុងទីដែលគួរឈប់ :

❖ សំចតមួយយប់។

**អំពី ចរិត មារយាទ ឫក ឫកពា**

**ចរិត** *ន.* (**សំ. បា.**) ការប្រព្រឹត្ត; កិរិយាមារយាទ, ឫកពា, បែបបទ :

❖ ចរិតល្អ

❖ ចរិតមិនល្អ។

**មារយាទ** *ន.* អាចារៈ, សណ្ដាប់ធ្នាប់, របៀប, របប, ឫក, ឫកពា :

❖ មារយាទថ្លៃ

❖ ឥតមារយាទ

❖ មានមារយាទ

❖ មារយាទថោក។

**ឫក, ឫកពា** *ន.* មារយាទ; កិរិយា, អាការកិរិយា, បែបបទ, សណ្ដាប់ធ្នាប់ *(របស់រូបកាយ)* :

❖ ឫកល្អ

❖ ឫកអាក្រក់

❖ ឫកសុភាព

❖ ឫកថ្លៃ

❖ ឫកចោក

❖ ធ្វើឫក

❖ វាយឫក

❖ ឫកពាសមរម្យ។

**អំពី ចិរភាព និរន្តរភាព**

**ចិរភាព** *ន.* ភាពយូរអង្វែង។

🌹 ភាពដែលអាចទ្រទ្រង់និងរីកចម្រើនទៅអនាគតបានវែងឆ្ងាយ :

❖ ការអភិវឌ្ឍប្រកបដោយចិរភាព។

**និរន្តរភាព** *ន.* ភាពដែលឥតមានចន្លោះ, ភាពដែលមានជានិច្ច, ភាពដែលឥតមានស្រាក, ភាពដែលឥតមានឈប់, ភាពដែលឥតមានល្ហែ :

❖ សូមលោកបានប្រកបដោយសេចក្ដីសុខជានិរន្តរភាព។

**អំពី ចែករំលែក ចែករំលែក**

**ចែករំលែក** *កិ.* ចែកឱ្យបានគ្រប់គ្នា។

**ចែករំលែក** *កិ.* ចែកដោយរំលែកឱ្យខ្លះ។

**អំពី ចេះ ចាំ ជ្រាប ដឹង យល់ ស្គាល់**

**ចេះ** *កិ.* ដឹងជាក់, យល់ជាក់ :

❖ ចេះអក្សរ។

**ចេះ** *កុ.* ឬ *ន.* ដែលមានចំណេះ :

- ❖ មនុស្សចេះ
- ❖ អ្នកចេះ។

**ចាំ** *កិ.* មិនភ្លេច, កត់ជាប់នៅក្នុងស្មារតីឬក្នុងការនឹកឃើញបានមិនភ្លេចភ្លាំង :

- ❖ ចាំធម៌
- ❖ ចាំច្បាប់
- ❖ ចាំមេរៀន។

**រង់ឬបង្អង់នៅមិនទៅណា** :

- ❖ ចាំខ្ញុំផង កុំអាលទៅ។

**នៅមើលថែរក្សា** :

- ❖ ចាំផ្ទះ
- ❖ ចាំចម្ការ។

**មានចិត្តប្រតិព័ទ្ធកួចកាន់ជានិច្ច** :

- ❖ ចាំចិត្ត (ចំពោះតែការស្នេហាមួយយ៉ាងប៉ុណ្ណោះ)។

ចាំជើង *កិ.* ដើរឬហួរ, បោលមិនល្អៀងឃ្លៀងឃ្លាតអំពីការបង្ហាត់ :

- ❖ គោដើរចាំជើង
- ❖ សេះលុនចាំជើង។

➭ (អ្នកស្រុកខ្លះប្រើពាក្យ ចាំជើង នេះចំពោះសត្វដែលឡើងពាក់លើគ្នាដោយមេថុនសេវនកិច្ចថា គោចាំជើង, សេះចាំជើង...)។

**ជ្រាប** *កិ.* ចូលសព្វសាច់, ហូរស្រក់ :

❖ ទឹកជ្រាប។

**ជ្រាប** *កិ.* ដឹង :

❖ សូមទ្រង់ជ្រាប

❖ សូមទានជ្រាប

❖ សូមជ្រាប

❖ បានជ្រាប (ប្រើចំពោះតែអ្នកដទៃ)។

**ដឹង** *កិ.* បានដំណឹង, ចូលចិត្តជាក់, ជ្រាបច្បាស់ក្នុងចិត្ត, យល់ជាក់ :

❖ ដឹងការណ៍ពិត។

**យល់** *កិ.* ឃើញដោយប្រាជ្ញា, គិតឃើញច្បាស់ :

❖ យល់ការខុសត្រូវ។

- យល់ចិត្ត : ឃើញជ្រៅដល់ទឹកចិត្ត
- យល់ព្រម : ព្រមតាម, អនុលោមតាម, ឃើញត្រូវជាមួយ
- យល់មុខ : ឃោគយល់ឬអត់ឱនដោយឃើញថាមានមុខមានឈ្មោះ, រើសមុខ :

❖ ឱ្យដោយយល់មុខ

❖ លម្នៀងព្រោះយល់មុខ...។

**ស្គាល់** *កិ.* ចាំបាន, ចាំជាក់, ចំណាំបាន, ដឹងបាន, ដឹងច្បាស់, ចាំស្និទ្ធ :

❖ ស្គាល់ផ្លូវ

❖ ស្គាល់គ្នា

❖ ស្គាល់ចិត្ត

❖ ស្គាល់ឈ្មោះ។

ស្គាល់គ្នា *គុ.* ដែលស្គាល់គ្នាជាក់ :

❖ មនុស្សស្គាល់គ្នា។

ស្គាល់ប្រមាណ : ដឹងប្រមាណ

ស្គាល់ត្វា : ស្គាល់ជិតដិតស្និទ្ធស្នាល ដូចជាសម្លាញ់ភ្ជា...។

## អំពី ចំណេះ វិជ្ជា

**ចំណេះ** *ន.* សេចក្ដីចេះ, ដំណើរដែលចេះ។

**វិជ្ជា** *ន.* (បា.) វិទ្យា, សេចក្ដីដឹងច្បាស់, ការចេះដឹង, ចំណេះ, វេទមន្ត, មន្តអាគម :

❖ វិជ្ជាលេខ

❖ វិជ្ជាពេទ្យ។

## ពាក្យភាព្យ

អ្នករៀនទាំងឡាយ ប្រយ័ត្នរាយមាយ ព្រោះក្ដីសល់វល់

ត្រូវខំមាត់រៀន ចំណេះសាកល ឱ្យត្រាតែដល់
ត្រើយត្រាណវិទ្យា។ ♒

វិទ្យាជាទ្រព្យ ប្រើបានគ្រប់សព្វ លើសទ្រព្យនានា
អ្នកមានទ្រព្យស្រាប់ អាប់ឥតវិជ្ជា មិត្តភក្តិផងគ្នា
គេច្រើនមើលងាយ។ ♒

## អំពី ច្បាប់ នីត វិន័យ

**ច្បាប់** *ន.* សេចក្តីបញ្ញត្តសម្រាប់ឱ្យអ្នកនគរប្រតិបត្តិតាម។

❀ វិន័យ, ក្រឹត្យក្រម, ក្បួនប្រដៅមនុស្សឱ្យប្រព្រឹត្តល្អ។ បែបយ៉ាង, គំរូយ៉ាង, គំរូ។ សេចក្តីដើម។

**នីត** *ន.* (**បា. សំ.**) ច្បាប់, ឧបាយជាគ្រឿងណែនាំ, បែបផែន,ទំនឹមទំនៀម, ប្រពៃណី។

✈ នីតិកម្ម : ការធ្វើច្បាប់, សិទ្ធិតែងច្បាប់, អង្គច្បាប់សម្រាប់រដ្ឋនីមួយៗ។

✈ នីតិកាល : កាលរបស់នីតិ, រយៈកាលរបស់សភាអ្នកតែងតាំងច្បាប់។

✈ នីតិកោសល : អ្នកឈ្លាសក្នុងច្បាប់, ដែលវាងវៃខាងច្បាប់។

✈ នីតិក្រម : លំដាប់នៃច្បាប់, ទម្រង់ការរបស់ច្បាប់គឺរបៀបដែលចៅក្រមត្រូវធ្វើក្នុងការ អង្កេតពិនិត្យសាកសួរពីបទល្មើសផ្សេងៗ។

នីតិនិយម : ការកំណត់យកតាមច្បាប់, សេចក្ដីស្មោះត្រង់ចំពោះច្បាប់រាជការសម្រាប់រដ្ឋ។

នីតិប្បញ្ញត្តិ : បញ្ញត្តិរបស់ច្បាប់, ការតែងតាំងច្បាប់, ការបង្គាប់ឱ្យធ្វើតាមច្បាប់។

នីតិបុគ្គល : អ្នករៀបរៀងច្បាប់, អ្នកតែងតាំងច្បាប់។

នីតិប្រតិបត្តិ : ការប្រតិបត្តិតាមច្បាប់, សេចក្ដីគោរពច្បាប់។

នីតិសម្បទា : ការដល់ព្រមដោយច្បាប់, ការសមប្រកបដោយច្បាប់, ការបរិបូណ៌ដោយច្បាប់, ការមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់។

នីតិសាស្ត្រ : គម្ពីរស្ដីពីច្បាប់, ក្បួនខ្នាតស្ដីពីច្បាប់។

**វិន័យ** *ន.* (**បា.សំ. វិនយ**) ការដឹកនាំទៅរកផ្លូវល្អ, ច្បាប់, ច្បាប់បញ្ញត្ត ឬច្បាប់អនុញ្ញាត, ច្បាប់ប្រដៅឱ្យប្រព្រឹត្តត្រឹមត្រូវ, ច្បាប់ប្រដៅឱ្យសង្រួមកាយវាចាឱ្យត្រឹមត្រូវ, ច្បាប់ប្រដៅឱ្យសង្រួមកាយវាចាឱ្យចុះបែបបទ, ច្បាប់ប្រដៅឱ្យសង្រួមកាយវាចាឱ្យមានសណ្ដាប់ធ្នាប់ល្អ, ច្បាប់សម្រាប់បព្វជិត :

- កាន់វិន័យ
- ខុសវិន័យ
- ធ្វើតាមវិន័យ។

## អំពី ជជែក ប្រឹក្សា ពិគ្រោះ ពិភាក្សា

**ជជែក** *កិ.* និយាយពិគ្រោះគ្នាឱ្យឃើញសេចក្ដីប្រាកដ។

**ប្រឹក្សា** *ន.* ការពិចារណា, ដំណើរស្ទង់ការ, ការល្បងមើលឱ្យឃើញពិត, ការពិគ្រោះគ្នា។

❀ ខ្មែរយើងច្រើនប្រើជា *កិ.* ពិគ្រោះគ្នា, ជជែកពិគ្រោះគ្នាឱ្យឃើញហេតុឃើញដំណើរ :

- ចាំប្រឹក្សាគ្នាសិន
- បានប្រឹក្សាយល់ព្រមគ្នាហើយ
- គណៈកម្មការបានប្រឹក្សាគ្នាអស់រយៈកាលដ៏យូរ...។

**ពិគ្រោះ** *កិ.* (**សំ.វិគ្រហ** *ន.* «ការប្រកាន់ខុសគ្នា, ការជជែកទាស់ដំណើរ គ្នា, ការធ្វើសេចក្តីឱ្យពិស្តារ, ការញែកសេចក្តី...») ប្រឹក្សាគ្នាឱ្យអស់អាថ៌ សេចក្តី, គិតគ្នាឱ្យអស់អាថ៌សេចក្តី, សាកសួរគ្នាឱ្យអស់អាថ៌សេចក្តី :

- ពិគ្រោះគ្នា
- ចាំពិគ្រោះគ្នាមើលសិន។

**ពិភាក្សា** *កិ.* (**សំ.វិវក្សា** ជា *ន.* «សេចក្តីប្រាថ្នា, បំណងចង់និយាយ, បំណងចង់ប្រឹក្សា») ជជែកពិគ្រោះគ្នា, ប្រឹក្សាគ្នា, ប្រឹក្សារកឱ្យឃើញខុស ត្រូវ :

- ចាំពិភាក្សាគ្នាមើលសិន
- ពួកចៅក្រមពិភាក្សាក្តី។

### អំពី ជញ្ជីង សញ្ជឹង

**ជញ្ជីង** *កិ.* រិះគិត, ត្រិះរិះ, ពិចារណា, រំពឹង, សម្រឹងទ្រឹងគិត។

**សញ្ញឹង** *កិ.* ឬ *កិ. វិ.* ទ្រឹងជញ្ជឹងគិតដោយអាការក្រៀមក្រំ :

❖ អង្គុយសញ្ជឹងធ្មឹងម្នាក់ឯង។

អំពី **ជាមួយ ជាមួយនឹង និង នឹង ព្រមទាំង មួយអន្លើដោយ ហ្នឹង**

**ជាមួយ** *និ.* រួមគ្នា, រួមផង, រួមផងដែរ :

❖ ទៅជាមួយគ្នា

❖ បរិភោគជាមួយគ្នា។

**ជាមួយនឹង** *និ.* ព្រមទាំងអ្នកដទៃឬអ្វីៗផង :

❖ បងនិយាយជាមួយនឹងប្អូន

❖ អ្នកទៅជាមួយនឹងខ្ញុំឬទេ?

❖ អ្នកណាខ្លះមកជាមួយនឹងអ្នក?

❖ គ្រូកំពុងនិយាយជាមួយនឹងនិស្សិតច្រើននាក់។

🕮 គួរកុំនិយាយថា **ទៅជាមួយខ្ញុំ, ស៊ីបាយជាមួយក្មេងៗ**...ដូច្នេះឡើយព្រោះ **ជាមួយ** មានវិធីប្រើផ្សេងគ្នាពី **ជាមួយនឹង**; **ជាមួយនឹង** នេះមានន័យស្មើគ្នានឹង **មួយអន្លើដោយ**។

**និង** *និ.* សព្ទជាសន្ធានជាទ្វន្ទ សម្រាប់និយាយតពាក្យឬតឃ្លារបះពីមួយទៅមួយដែលមានដំណើរសេចក្ដីថា ទាំង, ព្រមទាំង, ផង, នេះផង, នុះផង :

❖ អ្នកនិងខ្ញុំ

❖ សុខនិងទុក្ខ

- គោនិងក្របី
- ឱ្យនិងមិនឱ្យ
- ទៅនិងមិនទៅ
- យកចាននិងផ្តិលមកផង
- ផ្ទះនេះផ្ទះនុ៎ះនិងផ្ទះឯណោះ។

**នឹង** *អា. គិ.* ពាក្យប្រាប់ដំណើរសម្រេចនូវអំពើ, សម្រាប់ប្រើនិយាយនាំមុខនាមសព្ទ មានន័យថា :

**ដោយ; ជាមួយ, ដោយសារ; ព្ធដ៏, នៅត្រង់ :**

| | |
|---|---|
| ដួសសម្លនឹងវែក | : ដួសសម្លដោយវែក |
| ដាំបាយនឹងឆ្នាំង | : ដាំបាយដោយឆ្នាំង |
| កាប់ឈើនឹងពូថៅ | : កាប់ឈើដោយពូថៅ |
| ទៅនឹងខ្ញុំ | : ទៅជាមួយនឹងខ្ញុំ |
| នៅនឹងគេ | : នៅជាមួយនឹងគេ |
| ដេកនឹងគេ | : ដេកដោយសារគេ |
| ស៊ីនឹងគេ | : ស៊ីដោយសារគេ |
| ព្យួរអាវនឹងដែកែវ | : ព្យួរអាវព្ធដ៏ដែកែវ |
| បោះដែកគោលនឹងជញ្ជាំង | : បោះដែកគោលនៅត្រង់ជញ្ជាំង។ |

**ព្រមនាំង** *គិ.* មានទាំង, ថែមទាំង :

❖ អាពុកព្រមទាំងកូនផង។

**មួយអន្លើ** *និ.* ព្រមទាំង, ជាមួយ, ជាមួយនឹង (ត្រូវប្រើពាក្យ **ដោយ** ភ្ជាប់ខាងចុងផងជាដរាប) :

❖ព្រះរាជាទ្រង់ស្ដេចយាងទៅកាន់ជនបទ មួយអន្លើដោយព្រះរាជបរិពារ

❖ គ្រូចេញទៅលេងសួនច្បារ មួយអន្លើដោយសិស្សទាំងឡាយ។

**ហ្នឹង** *ទ. ស.* នុះ :

- ហ្នឹងឯង : នុះឯង
- ហ្នឹងហើយ : នុះហើយ
- ដំណើរហ្នឹង : ដំណើរនុះ។

**ហ្នឹង** *និ.* (ព. សា.) ដូច្នឹង, អ៊ីចឹង, អើ (អ្នកម្នាក់ប្រាប់ថា) :

❖ ទៅកុំខានហ្ន៎ះ! (អ្នកម្នាក់ឆ្លើយតបថា) ហ្នឹង!

- ហ្នឹងហើយ! : អ៊ីចឹងហើយ!
- ហ្នឹងឯង! : អ៊ីចឹងឯង!។

☞ បើនិយាយមានសំឡេងខ្ពស់ស្រួចខ្លាំង ត្រូវសរសេរដាក់ជើងក្អែក (+) នេះពីលើជា :

❖ ហ្នឹ៎ងឯ៎ង ! (សម្រាប់សម្ដីសាមញ្ញ)។

## អំពី ជាវ ទិញ លក់

**ជាវ** *កិ.* លក់, ទិញ (ពាក្យគោរព) :

❖ ជាវដី

❖ ជាវគម្ពីរ

❖ ជាវត្រៃចីវរ

❖ ជាវព្រះពុទ្ធរូប។

**ទិញ** ***កិ.*** បានអ្វីៗ មកជារបស់ខ្លួនដោយឱ្យថ្លៃជាប្រាក់ទៅអ្នកលក់ :

❖ទិញសំពត់

❖ ទិញសៀវភៅ។

**លក់** ***កិ.*** ចំណាយទំនិញ, ឱ្យរបស់ទៅអ្នកទិញដោយយកថ្លៃ :

❖ លក់ទំនិញ។

🕮 ពាក្យ **លក់** នេះប្រសិនបើរបស់ដែលទាក់ទងខាងព្រះពុទ្ធសាសនាត្រូវថា **ជាវ**, អ្នកលក់និងអ្នកទិញត្រូវថា **ជាវ** ដូចគ្នា :

❖ ជាវគម្ពីរ

❖ ជាវបាត្រ

❖ ជាវត្រៃចីវរ

❖ ជាវសៀវភៅធម៌...។

☞ ***ចំពោះបព្វជិតនិងអ្នកលក់ត្រូវថា*** ***ពិចារណា*** ដូចជា ថា :

❖ លោកគ្រូឱ្យគេពិចារណាតែបាត្រមួយទេឬឱ្យគេពិចារណាគ្រឿងបរិក្ខារអ្វីទៀតដែរ? ...។

## អំពី ជំនាញ ឯកទេស

**ជំនាញ** *គុ.* ដែលជាញ គឺដែលវាងវៃ, ប៉ិន, ប្រសប់, ស្ទាត់, ដែលចេះស្ទាត់ប្រាកដ :

❖ ត្រូវជ្រើសរើសយកសុទ្ធតែអ្នកជំនាញ

✈ អ្នកជំនាញការ : អ្នកប៉ិនធ្វើការ។

**ឯកទេស** *ន.* ភាគមួយ, ចំណែកមួយដែលត្រូវលើកយកមកនិយាយផ្សេងដោយឡែក :

❖ និយាយដោយឯកទេស។

**ឯកទេស** *គុ.* ពិសេស, ប្លែក :

❖ វត្ថុឯកទេស។

## អំពី ជំពូក ប្រការ ផ្នែក មាត្រា មាត្រា

**ជំពូក** *ន.* ចំណែក, ផ្នែក, វគ្គ :

❖ ត្រង់ជំពូកទី១ មានប្រការ៥

❖ ត្រង់ជំពូកទី២ មានប្រការ៧។

**ប្រការ** *ន.* (សំ.) ប្រភេទ, វិធី, បែប, បែបយ៉ាង, ទំនង,សេចក្តីដោយឡែក :

❖ សូមអ្នកបានប្រកបដោយសុខសួស្តី កុំបីឃ្លាតក្លាយទៅជាប្រការដទៃឡើយ!

**ផ្នែក** *ន.* ប៉ែក, សង្កាត់, ក្រុម :

❖ របស់នេះមួយផ្នែក

❖ របស់នោះមួយផ្នែក

❖ ផ្នែកទី១

❖ ផ្នែកទី២

❖ នាយផ្នែក។

**មាតិកា** *ន.* (ឆា.) ប្រឡាយ, ផ្លូវទឹក។

❀ ឧទ្ទេស, មេបទ គឺមេសេចក្តីដែលឱប ក្រសោបចំនួននិទ្ទេសបទឱ្យ ឋិតនៅក្នុងអំណាចខ្លួន (ទុកដូចជាមាតាដែលជា មេបន្ទុករបស់កូន) ខសំខាន់, គោលសង្ខេប :

❖ មាតិកាធម៌

❖ មាតិការឿង

❖ មាតិកាទី១ មាននិទ្ទេសបទ៤

❖ មាតិកាទី២ មាននិទ្ទេសបទ៥

❖ ចូរលើកយកមាតិកាធម៌មួយៗ មកអធិប្បាយឱ្យពិស្តារ។

**មាត្រា** *ន.* (សំ.) ការរាប់; ការថ្លឹង, ការស្ទង់; ការវាស់; ខ្នាតរង្វាស់យ៉ាងដូច ឈើរង្វាស់, ម៉ែត្រជាដើម។

✎ ខ្នាតសំឡេងអក្សរ : ស្គាល់មាត្រាអក្សរ។

**មាត្រា** *ន.* (សំ.) ប្រភេទសេចក្ដីដែលបែងចេញពីជំពូក, ប្រភេទសេចក្ដីដែលបែងចេញពីមាតិកា :

- ចាំមាត្រាច្បាប់
- កាត់សេចក្ដីអាងដល់មាត្រាច្បាប់។

## អំពី **ឈ្នាប់ ធ្នាក់**

**ឈ្នាប់** *ន.* ឈ្នាប់ជាពាក្យដែលគេប្រើសម្រាប់ភ្ជាប់ពាក្យទៅនឹងពាក្យកន្សោមពាក្យទៅនឹងកន្សោមពាក្យ ឬល្បះទៅនឹងល្បះ។

🕮 ពាក្យ **និង**, **ឬ**, **ប៉ុន្តែ**, **ព្រោះ**, **ពីព្រោះ**, **បើ**, ... ជាឈ្នាប់។

**ធ្នាក់** *ន.* ធ្នាក់ជាពាក្យសម្រាប់ប្រើជាមួយនឹងនាម កន្សោមនាម ឬកន្សោមកិរិយា ដើម្បីបង្កើតកន្សោមធ្នាក់ (កន្សោមមានធ្នាក់) :

- វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
- ក្នុងផ្ទះ
- ក្រៅផ្ទះ។

☞ ពាក្យ នៃ, លើ, ក្នុង, ក្រៅ, ជាមួយ, ជាមួយនឹង, ពី, អំពី, ដល់, ដោយ, ...ជាធ្នាក់។

## អំពី **ជន្ទ្រៃ ហៃ**

**ជន្ទ្រៃ** *កិ.* ឬ *កិ. វ.* រៀបរៀងគ្នាជាជួរតាមមុនក្រោយ មើលទៅឃើញមានរបៀបហូរហៃ :

❖ ដើរដង្ហែគ្នារជយ។

**ហែ** *កិ.* ដើរជាក្បួនចោមរោមមនុស្សឬអ្វីៗ ដែលត្រូវសម្ដែងសេចក្ដីគោរព ទៅរក :

❖ ហែនាគ

❖ ហែសព

❖ ហែកឋិន

❖ ហែព្រះពុទ្ធរូប។

**ហែ** *កិ.* រាជសព្ទ ជូនឬតាមជូនជាយសបរិវារ, ទៅឬមកកំដរគ្នា :

❖ ហែហ្លួង

❖ ហែព្រះករុណា

❖ ហែព្រះអង្គម្ចាស់។

**ហែ១** *កិ.* ដើរបណ្ដោយគ្នាជាជួរ :

❖ ដើរហែៗតាមគ្នា (ដើរដង្ហែគ្នា)។

**ហែ២** *ន.* ការដើរចោមរោមជារបៀប :

❖ ក្បួនហែ

❖ ទៅមើលហែ។

**ហែ៣** *កិ.* *វិ.* (ព. ប្រ.) ដែលមានតៗមកដូចគេដើរដង្ហែគ្នា, រៀងៗមកឥតអាក់ :

❖ មានហែៗមក។

## អំពី ដែរ ផង

**ដែរ** *និ.* ដូចគ្នា, បានដូចគ្នា, ផង, ដូចពាក្យថា :

- ❖ ខ្ញុំទៅដែរ
- ❖ ល្អគ្រាន់បើដែរ
- ❖ ដូច្នេះក៏បានដែរ
- ❖ អ្នកទៅជាមួយនឹងខ្ញុំដែរឬ?។

**ផង** *និ.* ជាមួយ, នឹង, ទាំង, ខ្លះ, ដែរ :

- ❖ ជួយគ្នាផង
- ❖ ឱ្យខ្ញុំទៅផង
- ❖ វាយផងជេរផង
- ❖ ចានផងឆ្នាំងផង
- ❖ ខ្វាក់ផងថ្លង់ផង។

## អំពី ដំណាច់ បំណាច់

**ដំណាច់** *ន.* ការដាច់, ដំណើរដាច់, អ្វីៗដែលដាច់ :

- ❖ ដំណាច់ខែ
- ❖ ដំណាច់ឆ្នាំចាស់។

**បំណាច់** *ន.* ថ្វីដៃ, ស្នាដៃ, ផលប្រយោជន៍ :

❖ ការនុះជាបំណាច់ដៃរបស់មាខ្ញុំ។ រង្វាន់ដែលគេឱ្យតបថ្នូរដៃអ្នកធ្វើការ, ថ្លៃនឿយហត់, រង្វាន់ឱ្យដោយឡែកផ្សេង, សគុណ :

➢ ប្រាក់៦០ ០០០រៀលនេះជាថ្លៃឈ្នួល

➢ ១០ ០០០រៀលនេះខ្ញុំឱ្យជាបំណាច់។

**បំណាច់** ***និ.*** ដ្បិត, បានជា, ដោយហេតុដែល :

❖ បំណាច់ហៅគ្នាមក គួរតែឱ្យអ្វីដល់គ្នាខ្លះទៅអេះ!

❖ លក់ឱ្យគាត់ខ្លះទៅ បំណាច់គាត់មក កុំឱ្យគាត់ទៅវិញទទេ!។

## អំពី **ដំណឹង ព័ត៌មាន**

**ដំណឹង** ***ន.*** សេចក្តីដែលឱ្យដឹង, សេចក្តីដែលដឹង, ការដឹង :

❖ ឮដំណឹង

❖ មានដំណឹង។

**ព័ត៌មាន** ***ន.*** (**សំ. វត៌មាន** «កាលឬសម័យដែលកំពុងប្រព្រឹត្តទៅ») ប្រព្រឹត្តិការណ៍, ដំណឹងផ្សេងៗក្នុងបច្ចុប្បន្ន, បច្ចុប្បន្នកាល :

❖ គេបានឱ្យព័ត៌មានមកថា...

❖ ស្តាប់ព័ត៌មានប្រចាំថ្ងៃនៃវិទ្យុជាតិ។

✍ សារព័ត៌មាន : ព័ត៌មានមានសារៈ គឺកាសែតដែលប្រាប់ដំណឹងគួរអានគួរដឹង។

## អំពី ដំណើរការ ដំណើរការណ៍

**ដំណើរការ** *ន.* វង់ការ, ប្រជុំមុខការ, ការដោយមុខ គឺការដោយឡែកពីគ្នា។

**ដំណើរការណ៍** *ន.* ដើងការ, ព័ត៌មាន, ទំនងឬលំនាំនៃរឿងរ៉ាវ, ស្ថានការណ៍, ស្ថានភាព, ហេតុភេទ, ដំណើរទំនង, រឿងហេតុដែលប្រព្រឹត្តទៅ :

- ❖ ដឹងដំណើរការណ៍
- ❖ ដំណើរការណ៍របស់ស្រុកទេស
- ❖ ចាំស្តាប់មើលដំណើរការណ៍សកលលោក
- ❖ ខ្ញុំមិនទាន់ទៅទេ ចាំស្តាប់ដំណើរការណ៍មើលសិន។

## អំពី តែ ប៉ុន្តែ

**តែ** *ឆិ.* ប៉ុន្តែ។

តែត្រឹម *និ.* ពាក្យជាសន្ធានសម្រាប់តសេចក្តី មានដំណើរផ្សេងៗ :

- ❖ សុំអ្នកឱ្យប្រាក់ថ្លៃភោជនាហារតែ១០ ០០០រៀលមកសិនចុះ...
- ❖ សងតែត្រឹម២ ៥០០រៀលមកទៀតគ្រប់ចំនួនហើយ។

**និបាតសព្ទប្រាប់សេចក្តីផ្សេងៗ មានដើម គឺជាសេចក្តីសរសើរក៏មាន :**

❖ សិស្សនេះសរសេរអក្សរពុំសូវល្អទេតែចេះតែងសេចក្តីត្រឹមត្រូវល្អណាស់។

**ជាសេចក្តីបង្អាប់, ជាសេចក្តីរិះគន់ :**

❖ ចេះសរសេរអក្សរល្អមែនទែន តែទាស់នឹងមានខុសច្រើនពេក។

- តែថា : ប៉ុន្តែថា
- តែបើ : ប៉ុន្តែបើ...។

**ប៉ុន្តែ** *ឆ.* តែថា :

- សេះនេះមាឌតូចទេ ប៉ុន្តែលឿនណាស់។

**អំពី តម្លៃ ថ្លៃ**

**តម្លៃ** *ន.* អ្វីៗដែលថ្លៃ, ប្រាក់ដែលត្រូវសងដល់អ្នកដទៃដោយខ្លួនបានទិញវត្ថុអ្វីៗពីគេ :

- ចុះតម្លៃ
- សងតម្លៃ
- អស់តម្លៃ
- របស់មានតម្លៃ។

**ថ្លៃ** *គុ.* ឬ *កិ. វិ.* ដែលមានតម្លៃ :

- កាលពីដើមក្រប្រាក់ណាស់, ស្រូវ១ហាបថ្លៃ៣រៀល
- ប្រអប់នេះថ្លៃណាស់
- លក់ថ្លៃណាស់។ *ព. ផ្ទ.* ថោក។

**ថ្លៃ** *ន.* តម្លៃ :

- ទំនិញឡើងថ្លៃ
- របស់នេះថ្លៃប៉ុន្មាន?

❖ ត្រូវសួរឱ្យដឹងថ្លៃសិន។

## អំពី ទំនឹម ភាសិត សុភាសិត ស្លោក

**ទំនឹម** *ន.* ឬ *គុ.* ពាក្យដែលផ្ទឹមនឹងពាក្យឯទៀត :

❖ ពាក្យទំនឹម។ ច្រើនប្រើជាបរិវារសព្ទផ្សំជាមួយនឹងពាក្យទំនៀម :

**ទំនឹមទំនៀម** គឺពាក្យលោកចងជាប្រស្នាប្រៀបផ្ទឹមទៅរកសេចក្ដីណាមួយ, ច្រើនតែជាពាក្យសុភាសិត, ដូចពាក្យមានដើមថា :

➥ ចិត្តជាទេវទត្ត មាត់ជាទេវតា។

**ភាសិត** *ន.* (បា.) ពាក្យ, សម្ដី។

**ភាសិត** *គុ.* (បា.) ដែលគេពោលហើយ, ដែលនិយាយហើយ។

ប្រើផ្សំចូលនឹងនាមនាមឯទៀតក៏បានដូច :

ពុទ្ធភាសិត : ពាក្យព្រះពុទ្ធ, ពាក្យដែលព្រះពុទ្ធទ្រង់ត្រាស់សម្ដែងហើយ។

សុភាសិត : ពាក្យពីរោះ, ពាក្យត្រឹមត្រូវ, សម្ដីដែលគេនិយាយត្រូវ, ពាក្យប្រដៅល្អ។

ទុព្ភាសិត : ពាក្យអាក្រក់, សម្ដីដែលនាំឱ្យប្រព្រឹត្តអាក្រក់។

**សុភាសិត** *គុ.* (បា.) ដែលពោលពីរោះ, ដែលនិយាយត្រូវ, ដែលថាត្រូវ (នាំឱ្យសម្រេចប្រយោជន៍បានដោយប្រពៃ) :

❖ ពាក្យសុភាសិត

❖ កាព្យសុភាសិត។

**សុភាសិត** *ន.* (បា.) ពាក្យពីរោះ, ពាក្យត្រូវ, ឱវាទត្រឹមត្រូវ (ដែលមានប្រយោជន៍គួររៀនគួរស្ដាប់) :

▦ **មានសុភាសិតបុរាណថា** អួសទូកកុំឱ្យល្អាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក :

➥ ធ្វើអ្វីៗកុំឱ្យមានមោះហ្មងហើយឱ្យកើតការដោយស្រួលផង...។

**ស្លោក** *ន.* (សំ.) សេចក្ដីសរសើរ, ពាក្យសរសើរ, ពាក្យកាព្យសម្រាប់សូត្រសរសើរគុណ, ឆន្ទ, គាថា ជាភាសាសំស្ក្រឹតឬបាលី, កេរ្ដិ៍ឈ្មោះល្អ។

❀ ខ្មែរច្រើនប្រើសំដៅពាក្យរៀលសម្រាប់ទាយលក្ខណៈមនុស្សជាដើម ដូចជា ដំហរ សិង្ហ សម្លឹងខ្លា សំឡេងស្វា ភ្នែកមាន់ព្រៃ (ទាយថា មនុស្សម្នាក់បើប្រកបព្រមដោយលក្ខណៈទាំង៤យ៉ាងនេះ ជាអ្នកមានបុណ្យ មានអំណាចចិត្តមុត)។

មានពាក្យសុភាសិតថា កុំយកពាក្យស្លោកផ្ទឹមនឹងគម្ពីរ។

**អំពី ទម្លាប់ ទំនៀម ប្រពៃណី**

**ទម្លាប់១** *កិ.* ធ្វើឱ្យធ្លាប់, ធ្វើឱ្យថ្នឹក :

❖ ទម្លាប់ដៃ

❖ ទម្លាប់ខ្លួន

❖ ទម្លាប់ចិត្ត

❖ ទម្លាប់មាត់...។

**ទម្លាប់២** *ន.* ការដែលធ្លាប់, លំអានដែលធ្លាប់តែមានមក :

❖ ទម្លាប់ចាស់បុរាណ

❖ ធ្វើតាមទម្លាប់ពីមុនមក

❖ មានទម្លាប់ពីនាយមក...។

**ទំនៀម** *ន.* បវេណី, ធម្មតា, សណ្ដាប់, សណ្ដាប់ធ្នាប់, ទម្លាប់, បែបបទ :

❖ ធ្វើតាមទំនៀម។

**ប្រពៃណី** *ន.* ទំនៀម, ពូជពង្ស, តំណវង្សត្រកូល :

❖ រក្សាប្រពៃណី

❖ ធ្វើបុណ្យទានតាមប្រពៃណី។

បវេណីទេវតា : ទេវតាដែលគេរាប់អានតាមតំណវង្សត្រកូលតៗមក។

រួមបវេណី : រួមសុខទុក្ខរបស់ស្វាមីភរិយា។

## អំពី ទ្រព្យ សម្បត្តិ

**ទ្រព្យ** *ន.* វត្ថុ, ធនធាន, សម្បត្តិ...។

ខ្មែរយើងប្រើពាក្យនេះចំពោះតែវត្ថុមានមាសប្រាក់ជាដើមដែលមានម្ចាស់។

ទ្រព្យធន : ទ្រព្យផ្សេងៗ, ទ្រព្យសម្រាប់ប្រើប្រាស់

ទ្រព្យសម្បត្តិ : ទ្រព្យផ្សេងៗ, ទ្រព្យសម្រាប់ប្រើប្រាស់, ទ្រព្យធន។

**សម្បត្តិ** *ន.* (បា. សំ.) សេចក្ដីសម្រេច, ការសមប្រកប; ការបរិបូណ៌, ការគ្រប់ព្រម, ការគ្រប់គ្រាន់,សេចក្ដីសុខ, លម្អ, គុណភាព, ទ្រព្យ, ធនធាន :

- មានសម្បត្តិ
- សម្បត្តិសួគ៌
- សម្បត្តិនិព្វាន
- សម្បត្តិមនុស្ស។

**អំពី និបាតសព្ទ អាយតនិបាត**

**និបាតសព្ទ** *ន.* សព្ទសម្រាប់ផ្សំសម្ដីត្រង់ឃ្លារបះនីមួយៗ ជាជំនួយនាមសព្ទ និងកិរិយាសព្ទឱ្យមានសេចក្ដីស្រលះ, ច្បាស់លាស់, ពីរោះស្រួលស្ដាប់...។

📖 ដូចពាក្យថា ក៏, ក៏ដោយ, ក៏ដែរ, ក្ដី, ផង, ឯ, បើ, ទោះ, ទោះបី, បើទុកជា, ទើប, ពុំនោះសោត, ដែរ ជាដើម (ព. វ.)។

**អាយតនិបាត** *ន.* (សំ. បា. **អាយត** «ដែលញែកឬវាតចេញឱ្យទូលាយ» + **និបាត** «និបាតសព្ទ») ទីបំផុតនៃនាមសព្ទដែលសម្រេចដោយវិភត្តិនាម ស្រេចហើយឬពាក្យប្រែរបស់វិភត្តិនាម, ដូចជា វិបុរស, នូវបុរស, ដែលបុរស, ដល់បុរស, នៃបុរស ជាដើម, វិ, នូវ, ដែល, ដល់, នៃ ជាអាយតនិបាត (ព.វ.)...។

**ពាក្យកាព្យ**

និបាតពួកនេះទាំងប៉ុន្មាន　　អ្នកប្រើស្មានៗច្រើនតែភ្លាត់
**នៃ-នូវ-ដល់**-ដោយគួរប្រយ័ត្ន　　កុំឱ្យវិបត្តិខូចសេចក្ដី។

គួរអ្នកស្រលាញ់អក្សរជាតិ កុំប្រើឱ្យឃ្លាតចាកវិធី
គួរធ្វើសម្ពន្ធឱ្យខ្ចេចខ្ចី ឈ្លេចឈ្លើជាមុនសិនសឹមប្រើ។
ពាក្យដល់និងនៃសេចក្ដីផ្សេង ជូនភ័ន្តវង្វេងប្រើសើៗ
បែរមានសេចក្ដីប៉ះទៅលើ ក្ដីច្នេះសោះតើជាច្នោះវិញ។៚

**អំពី និព្វាន បរិនិព្វាន**

**និព្វាន** *ន.* អស់មានកម្មដដែលៗតទៅទៀតហើយ (សំដៅចំពោះ **ខន្ធនិព្វាន** របស់ព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះអរហន្តខីណាស្រព, ប៉ុន្តែពាក្យ **និព្វាន** នេះមាន **មគ្គ៤ ផល៤** ជាប្រភពឱ្យកើតបានជា **កិលេសនិព្វាន** ក៏ពុំទាន់ផុតស្រលះចាកកម្មដដែលៗនៅឡើយ លុះដល់បញ្ចក្ខន្ធរលត់ហើយទើបមានឈ្មោះថា **ខន្ធនិព្វាន** អស់មានកម្មដដែលៗតទៅទៀតនៅមានសុទ្ធតែ **បរមសុខ** ហៅថា **ឯកន្តបរមសុខ** តែមួយយ៉ាងប៉ុណ្ណោះឯង។

🕯 **និព្វាន** គឺជាបរមត្ថធម៌មានអត្ថន័យសុខុមល្អិតហួសវិស័យនៃសាធារណសត្វបុថុជ្ជន បើលុះតែបុថុជ្ជនអ្នកធុញទ្រាន់នឿយណាយរសាយចិត្តឃ្លាតចាកកម្មដដែលៗ ទើបយល់ឃើញព្រឹលៗ ថាមាននិព្វានពិតមែន ...(ព.វិ.ព.)។

**បរិនិព្វាន** *ន.* អស់ខ្យល់ដង្ហើម, អស់ជីវិត។

❀ **ទេព.**ស្លាប់, សោយទិព្វជង្គត, សោយទិវង្គត, សោយពិរាល័យ, សុគតឬសុរគត, ក្ស័យ, ក្សិណក្ស័យ; ទទួលអសញ្ញកម្ម ឬទទួល

អសញ្ញាភាព; ទទួលមរណភាព; ទទួលអនិច្ចធម្ម; ទទួលអនិច្ចកម្ម; ធ្វើកាលកិរិយា; រលត់, រលត់ខន្ធ, រំលាងខន្ធ, ផ្លាយខន្ធ, ផ្លាយសង្ខារឬបែកធ្លាយសង្ខារ, បាត់បង់, ដើរ, ផុត, ផុតរលត់, ដាច់ខ្យល់, អស់ដង្ហើម, ងាប់, តាយសាក, តាយហោង, ស្អឹង, តាយស្អឹង, តេន (ប្រើ តាមថ្នាក់ ខ្ពស់, កណ្ដាល, ទាបនិងសាមញ្ញ)។

## អំពី និស្ស័យ ឧបនិស្ស័យ

**និស្ស័យ** *ន.* ការនៅអាស្រ័យក្រោមឱវាទនិងក្រោមការគ្រប់គ្រងនៃអ្នកដទៃ។

✎ សូមនិស្ស័យ *កិ.* សូមនៅអាស្រ័យក្រោមឱវាទនិងក្នុងការឧបត្ថម្ភ, ការសង្គ្រោះដោយពុំបណ្ដែតបណ្ដោយ, ពុំមើលបំណាំ :

❖ មានព្រះពុទ្ធប្បញ្ញត្តិថា សាមណេរត្រូវសូមនិស្ស័យនឹងភិក្ខុអ្នកចេះវិន័យហើយនៅក្នុងការគ្រប់គ្រងរបស់លោកជានិច្ច...(ព. វិ. ពុ.)។

✎ ឱ្យនិស្ស័យ : ទទួលឱ្យនៅជ្រកអាស្រ័យ។

✎ គ្មាននិស្ស័យនឹងគ្នា : គ្មានការនៅជ្រកអាស្រ័យអ្វីនឹងគ្នាឡើយ។

✎ អស់និស្ស័យនឹងគ្នា : អស់មានការប្រាស្រ័យគ្នាតទៅទៀត។

✎ និស្ស័យ *ន.* ជនជាពំនាក់, ជាអ្នកទំនុកបម្រុង :

↳ ***ខ្ញុំបែកបជំនួញធំពុំកើតព្រោះគ្មាននិស្ស័យ***: គ្មានអ្នកទំនុកបម្រុង។

**ឧបនិស្ស័យ** *ន.* កុសលធម៌ដែលដេកឬអាស្រ័យនៅក្នុងខន្ធសន្ដាន គឺកុសលដែលបានកសាងសន្សំអប់រំទុកមក, សំណាង, ភ័ព្វព្រេងសំណាង, ចំណុចចិត្ត។

✎ មានឧបនិស្ស័យបរិបូរ : មានកុសលក្រាស់ក្រែល។

☞ **ក្នុងគម្ពីរពុទ្ធសាសនាថា ឧបនិស្ស័យ មាន៣យ៉ាង :**

***១- ទានូបនិស្ស័យ*** : សំណាងដែលបានសាងទុកមកដោយការបរិច្ចាគទ្រព្យធ្វើទាន។

***២- សីលូបនិស្ស័យ*** : សំណាងដែលបានសាងទុកមកដោយការរក្សាសីល។

***៣- ភាវនូបនិស្ស័យ*** : សំណាងដែលបានសាងទុកមកដោយភាវនា។

**អំពី និស្សិត សិក្ខាកាម សិស្ស**

**និស្សិត** *ន.* (បា.) អ្នកដែលនៅក្នុងនិស្ស័យគេ, អ្នករៀនដែលនៅក្នុងការគ្រប់គ្រងនៃគ្រូ។ ព្យញ្ជនៈដែលអាស្រ័យនឹងស្រះ *(ព. វ.)*។

**សិក្ខាកាម** *ន.* (បា) អ្នកដែលពេញចិត្តកាន់តាមសិក្ខា, អ្នកស្រលាញ់ការសិក្សា។

**សិស្ស** *ន.* (បា.) អ្នករៀនចំណេះពីគ្រូ, អ្នកដែលគ្រូត្រូវបង្ហាត់បង្រៀនឬត្រូវប្រៀនប្រដៅ។

- សិស្សគណ : គណៈសិស្ស, ពួកសិស្ស
- សិស្សបំបួស : សិស្សដែលឧបជ្ឈាយ៍ឬអាចារ្យបំបួសជាសាមណេរ។
- សិស្សបួស : សិស្សរបស់ពេទ្យហួ, សិស្សថ្នាំសង្កូវ។
- សិស្សវត្ត : សិស្សដែលនៅរៀនក្នុងវត្ត។
- សិស្សសាលា : សិស្សដែលរៀនក្នុងសាលារាជការ។
- សិស្សសិប្ប: : សិស្សរៀនសិប្បៈ។
- សិស្សសិល្ប៍ : សិស្សរៀនសិល្បៈ, សិស្សសិប្បៈ។

✈ សិស្សសូត្រ : សិស្សរបស់លោកគ្រូសូត្រ។

**អំពី នីតិជន នីតិបុគ្គល**

**នីតិជន** *គ.* (ច្បា.) អ្នកដែលមាននីតិភាព, បុគ្គលដែលច្បាប់ទទួលស្គាល់ថាគ្រប់អាយុអាចទទួលខុសត្រូវចំពោះអំពើគ្រប់បែបយ៉ាងរបស់ខ្លួន :

❖ មនុស្សដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចុះកិច្ចសន្យានិងទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

**នីតិបុគ្គល** *គ.* មនុស្សមួយក្រុមដែលច្បាប់សន្មតថាជាបុគ្គល, ក្រុមនៃមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គល ប៉ុន្តែដទៃពីសមាជិកនៃខ្លួន, អង្គភាពដែលមិនមែនជាមនុស្ស ឬជាអង្គការមួយដែលច្បាប់ដាក់និយមន័យច្បាស់លាស់ហើយចាត់ទុកជាបុគ្គលក្នុងគោលដៅនៃច្បាប់តែប៉ុណ្ណោះ។

❖ មន្ទីរពេទ្យ

❖ សមាគមចិន

❖ សាកលវិទ្យាល័យ

❖ ក្រុមហ៊ុនផលិតស្រា

❖ ក្រុមហ៊ុននាំចេញនាំចូល

❖ សមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ។

## អំពី បង្រៀន បង្ហាត់

**បង្រៀន** *កិ.* ញុំាងអ្នកដទៃឱ្យរៀន, ប្រៀនឱ្យចេះ, ប្រៀនឱ្យចំណេះដោយការបង្ហាត់, បង្ហាញឱ្យចេះ :

- ❖ បង្រៀនលេខ
- ❖ បង្រៀនអក្សរ
- ❖ បង្រៀនច្បាប់។

**បង្ហាត់** *កិ.* ប្រើឱ្យហាត់, ប្រិតប្រៀនបង្វឹកឱ្យបានបទ :

- ❖ បង្ហាត់កីឡា
- ❖ បង្ហាត់ធម៌។

## អំពី បម្រាប បម្រាប់

**បម្រាប** *កិ.* ប្រាបឱ្យរាប, ប្រាបឱ្យបាក់ស្បាត :

- ❖ បម្រាបសត្រូវ។ (*ដរ.* **ពង្រាប, បង្ក្រាប។**)

**បម្រាប** *ន.* ដំណើរប្រាបឱ្យរាប, ការប្រាបឱ្យរាប :

❖ ពួកហ្នឹងឥឡូវវារបះរបើងឡើងវិញទៀតហើយ ត្រូវប្រតិបត្តិការតាមលំអានច្បាប់បម្រាបមុន ទើបកើត។

**បម្រាប់** *ន.* ការប្រាប់, ការប្រាប់ឱ្យធ្វើតាម :

- ❖ បម្រាប់ក្រសួង
- ❖ បម្រាប់របស់មាតាបិតា

❖ បម្រាប់ត្រូវតាមផ្លូវច្បាប់។

## អំពី បរិយាយ អធិប្បាយ

**បរិយាយ** *ន.* (បា.) សេចក្តីអធិប្បាយដោយផ្សេងៗ, ការអធិប្បាយសម្រួលសេចក្តី :

❖ ពោលដោយបរិយាយ។

**អធិប្បាយ** *ន.* (បា.) ការពន្យល់សេចក្តីដោយមានគ្រឿងអាង, សេចក្តីពន្យល់មានអាង, សេចក្តីពន្យល់មានពស្តុតាង, សេចក្តីពន្យល់មានគោល :

❖ យល់តាមអធិប្បាយ។

❀ ខ្មែរប្រើជា *កិ.* ឬ *គុ.* ក៏បាន :

❖ ពាក្យអធិប្បាយ

❖ អធិប្បាយឱ្យងាយយល់។

## អំពី បាឋកថា សន្ទកថា សុន្ទរកថា

**បាឋកថា** *ន.* (បា. សំ.) សម្តីថ្លែងសេចក្តី (មាត់ទទេ), កថាសម្តែងរឿងរ៉ាវ, កថាសូត្របាលី។

☞ (អ្នកប្រទេសឥណ្ឌាហៅសាលារៀនថា **បាឋសាលា** តាមការយល់របស់គេ)។

**សន្ទកថា** *ន.* (បា. សំ.) ពាក្យសន្ទនា, ការសន្ទនាគ្នា, ការថ្លែងសេចក្តីមាត់ទទេ :

❖ ធ្វើសង្កថារកគ្នាទៅវិញទៅមក។

**សុន្ទរកថា** *ន.* (បា. សំ.) សម្ដីពីរោះ, សម្ដីគួរចង់ស្ដាប់។

❀ ខ្មែរហៅសម្ដីសូត្រថ្លែងសេចក្ដីក្នុងទីប្រជុំជនថា **សុន្ទរកថា** ដែរ :

❖ សូត្រសុន្ទរកថាក្នុងមហាសន្និបាត...។

**អំពី បុគ្គលិក សហការី សហសេវក**

**បុគ្គលិក** *គុ.* (បា.) ដែលចំពោះបុគ្គលឬសម្រាប់បុគ្គលម្នាក់ៗ មិនមែនជាសាធារណៈទូទៅ :

❖ របស់បុគ្គលិក។

**បុគ្គលិក** *ន.* (បា.) ភ្នាក់ងាររាជការដែលធ្វើការក្នុងក្រសួងរាជការផ្សេងៗ ឬនិយោជិតនៃគ្រឹះស្ថានពាណិជ្ជកម្មជាដើម :

❖ បុគ្គលិកទិនិក

❖ បុគ្គលិកក្នុងក្របខណ្ឌ។

**សហការី** *ន.* (បា.) អ្នកធ្វើការជាមួយគ្នា, អ្នកព្រួតគ្នាជួយធ្វើកិច្ចការណាមួយ, ភ្នាក់ងារក្នុងមុខតំណែងរាជការជាដើម :

❖ នាយការិយាល័យនិងលេខាធិការ ជាសហការីនៃនាយកក្រសួង។

❖ លោករដ្ឋមន្ត្រីព្រមទាំងសហការីបានអញ្ជើញទៅជួបជុំជាអធិបតីក្នុងពិធីបុណ្យនោះដែរ។

❖ ព្រះបាឡាត់គណ, ព្រះវិន័យធរគណ, ព្រះធម្មធរគណ, ព្រះសមុហ៍គណនិងលេខាធិការគណជាសហការីនៃព្រះមេគណ។

❖ ព្រះមេគណគ្រប់ខេត្តអាចមានឋានានុក្រមទីព្រះគ្រូជាសហការីផង ដែរក៏បាន។

**សហសេវក** *ន.* (បា.) អ្នកកាន់ឧត្តមគតិដូចគ្នា, អ្នកមានចិត្តគំនិតត្រូវគ្នា :

❖ លោកឫទ្ធិជាសហសេវិករបស់ខ្ញុំ។

## អំពី បុព្វកថា អារម្ភកថា

**បុព្វកថា** *ន.* (បា.) ពាក្យនិយាយខាងដើមសៀវភៅ, ពាក្យផ្ដើមជាដំបូង, អារម្ភកថា, អារម្ភបទនៃសៀវភៅ។

**អារម្ភកថា** *ន.* (បា. សំ.) ពាក្យប្រារព្ធ, ពាក្យផ្ដើម, ពាក្យនាំមុខ :

❖ អារម្ភកថាសៀវភៅ...។

## អំពី បុព្វហេតុ មូលហេតុ

**បុព្វហេតុ** *ន.* (បា.) ហេតុដើម, ដំណើរដើម គឺហេតុដែលបណ្ដាលឡើង ជាមុនឬដែលផ្ដើមឡើងជាមុន។

**មូលហេតុ** *ន.* (បា.) ហេតុដើម, ដំណើរដើម...។

## អំពី បេសកកម្ម បេសិតកម្ម

**បេសកកម្ម** *ន.* អំពើរបស់ជនអ្នកប្រើឬកិច្ចការរបស់ជនអ្នកចាត់ការបញ្ជូន។

**បេសិតកម្ម** *ន.* អំពើរបស់ជនត្រូវគេប្រើឬកិច្ចការរបស់ជនអ្នកទទួលបម្រើ។

## អំពី បេសកជន បេសិតជន

**បេសកជន** *ន.* ជនអ្នកប្រើ, ជនអ្នកបញ្ជូន។

❀ ជនដែលទទួលភារៈទៅបំពេញបេសកកម្ម, ភ្នាក់ងារដែលគេចាត់ប្រើឱ្យទៅបំពេញបេសកកម្មអ្វីនីមួយនៅទីដទៃ។

**បេសិតជន** *ន.* ជនដែលត្រូវគេប្រើឬជនអ្នកទទួលបម្រើ។

## អំពី ប្រជុំ សន្និបាត សន្និសីទ សមាជ សិក្ខាសាលា

**ប្រជុំ** *កិ.* ធ្វើឱ្យជុំគ្នា, ប្រមូលឱ្យចួបជុំគ្នា, មកចួបជុំគ្នា :

- យើងនឹងប្រជុំគ្នាព្រឹកស្អែកពេលម៉ោង៨នៅទីនេះ។
- ប្រជុំជន : ពួកជនដែលកំពុងប្រជុំគ្នា។
- ទីប្រជុំ : ទីដែលចួបជុំគ្នា។
- ប្រជុំជាតក : ប្រជុំរឿងក្នុងអតីតជាតិ។

**សន្និបាត** *ន.* (បា.) ការប្រជុំ, ការចួបជុំ, ការប្រមូលរួបរួមគ្នា, ការលាយផ្សំគ្នា :

- ធ្វើសន្និបាត។
- ក្នុងសន្និបាត : ក្នុងទីប្រជុំ។
- ក្រុមសន្និបាត : ក្រុមអ្នកប្រជុំធ្វើការរួមគ្នា, ក្រុមជំនុំ។
- ទីសន្និបាត : ទីប្រជុំ។
- សន្និបាតជាតិ *ន.* ជាតិមនុស្សផ្សេងៗគ្នាដែលរួបរួមទុកដូចជាជាតិមួយនៅក្នុងអំណាចច្បាប់រាជការតែមួយ :
- ពួកសន្និបាតជាតិ។

**សន្និសីទ** *ន.* (**បា.**) ពាក្យនេះតាមបាលី គឺមានន័យដូចគ្នានឹង **សន្និស័ន** ដែរ ប៉ុន្តែសព្វថ្ងៃនេះ ខ្មែរយើងប្រើសំដៅយកការប្រជុំគ្នាដជែកពិភាក្សាអំពីបញ្ហាផ្សេងៗដែលឋិតនៅក្នុងសភាពស្មុគស្មាញមិនទាន់ដាច់ស្រេច ដើម្បីរិះរកផ្លូវចេញឬដោះស្រាយឱ្យជ្រះស្រលះ, ការថ្លែងសេចក្ដីពន្យល់អំពីបញ្ហាផ្សេងៗដល់សាធារណជន :

- ធ្វើសន្និសីទ
- ស្ដាប់សន្និសីទ។

**សមាជ** *ន.* (**បា. សមជ្ជ ឬ សមជ្ជា**) មហាសន្និបាតឬការប្រជុំនៃមហាជនអ្នកពិភាក្សាអំពីបញ្ហាផ្សេងៗដែលមានផលប្រយោជន៍ទូទៅ :

- សមាជបានពិភាក្សាបញ្ហានោះអស់កាលដ៏យូរ។
- សមាជជាតិ : សមាជរបស់ជាតិ។

**សិក្ខាសាលា** *ន.* កន្លែងរៀនខាងវិជ្ជាជីវៈអ្វីមួយ :

- ក្រុមហ៊ុនបារាំងបានបង្កើតសិក្ខាសាលាជាច្រើនកន្លែង។

**សិក្ខាសាលា** *ន.* វគ្គបណ្ដុះបណ្ដាលមួយធ្វើដោយគំហុកឬជាការជួបប្រជុំដោះស្រាយបញ្ហាសម្រាប់អ្នកចូលរួមមួយក្រុមតូច ដឹកនាំដោយគ្រូបង្ហាត់អ្នកសម្របសម្រួលម្នាក់។

## អំពី ច្រាប ច្រាប់

**ច្រាប** *កិ.* ធ្វើឱ្យរាប, ធ្វើឱ្យបាក់បប, ធ្វើឱ្យចុះចាញ់ :

❖ ប្រាបសឹក

❖ ប្រាបសត្រូវ។

ប្រាបប្រាម *កិ.* ប្រាមប្រាបឱ្យរាបទាប, ប្រាមប្រាបឱ្យស្ដាប់ឱវាទ។ **ប្រាប់** *កិ.* និយាយឱ្យដឹងចំពោះមុខ, និយាយឱ្យដឹងផ្ទាល់ខ្លួន, ថ្លែងឱ្យដឹង។

**អំពី ផ្លាក ស្លាក**

**ផ្លាក** *ន.* (ពាក្យខ្ចីពីបារាំង Plaque) សន្លឹកធ្វើអំពីលោហៈ ឈើ ឬរបស់ផ្សេងៗទៀតដែលមានលក្ខណៈរឹង សំប៉ែត តូចជាងផ្ទាំងនិងមានរាងផ្សេងៗ ប៉ុន្តែជាទូទៅច្រើនមានរាងចតុកោណ សម្រាប់ប្រើកត់ត្រាសម្គាល់លេខរថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត គេហដ្ឋាន តួនាទី កន្លែងធ្វើការ...។

**ស្លាក** *ន.* សំបុត្រជាកំណាត់តូចៗជាគ្រឿងសម្គាល់ឈ្មោះជាដើម, ឆ្នោត, ទីវ, ខ្នាច់ :

❖ ចាប់ស្លាក

❖ សរសេរស្លាក

❖ បិទស្លាកជាសម្គាល់

❖ ដាក់ស្លាកជាសម្គាល់កុំឱ្យច្រឡំ។

ដោយយោងទៅលើនិយមន័យនៃពាក្យខាងលើ «**ស្លាក**» មិនអាចប្រើជំនួស «**ផ្លាក**» បានឡើយ ពីព្រោះតែវាជា «**កំណាត់តូចៗ**» រីឯ «**ផ្លាកសញ្ញា**» ដែលមានលក្ខណៈរឹង មិនអាចគ្របដណ្ដប់លើ «**ចជា**»

ដែលមានលក្ខណៈទន់បានឡើយ។ ដើម្បីគ្របដណ្ដប់លើសញ្ញាផ្សេងៗដែលក្នុងនោះមាន «**បដា**» ផង។ ប៉ុន្តែតាមវចនានុក្រមនេះ «**សញ្ញាប័ដ**» ជា «**ដំបាររឬបន្ទះស្លាក់**» (...) ដូច្នេះពាក្យនេះក៏មិនអាចគ្របដណ្ដប់លើ «**បដា**» បានដែរ គួរយើងយកពាក្យ «**រូបសញ្ញា**» វិញដើម្បីគ្របដណ្ដប់លើសញ្ញាផ្សេងៗដែលមាន «**បដា**» ផង ហើយរូបសញ្ញាមាន :

- បដា
- ប៉ាណូ
- ប៉ង់កាត
- អាហ្វីស
- និមិត្តសញ្ញា
- ផ្លាកយីហោ
- ពាណិជ្ជនាម
- បណ្ណប្រកាស
- ពាណិជ្ជសញ្ញា
- លក្ខណៈសញ្ញា
- ផ្លាកពាណិជ្ជកម្ម
- អក្សរចារឹកនៅតាមទីសាធារណៈ...។

## អំពី ពន្លត់ រលត់ រំលត់

**ពន្លត់** *កិ.* ធ្វើឱ្យរលត់, រំលត់ :

- ❖ ពន្លត់ភ្លើង
- ❖ ពន្លត់ចង្កៀង

▦ ប្រើចំពោះតែញ៉ាំងពន្លឺភ្លើងឱ្យរលត់, បើខាងទុក្ខព្រួយឬកំហឹងជាដើមវិញ ត្រូវប្រើពាក្យ **រំលត់** :

- ❖ រំលត់ទុក្ខ
- ❖ រំលត់ក្រោធ
- ❖ រំលត់កិលេស។

**រលត់១** *កិ.* កិរិយាសព្ទជាកត្តុវាចក (សម្រេចអំពើខ្លួនឯង) ចេញទៅជាកិរិយាសព្ទជាហេតុកត្តុវាចក (ញ៉ាំងអ្នកដទៃឱ្យសម្រេចអំពើ) វិនាសបាត់ពន្លឺ, វិនាសបាត់កម្ដៅ :

- ❖ ភ្លើងរលត់
- ❖ ចង្កៀងរលត់។

**រលត់២** *កិ.* ស្លាប់ :

- ❖ ខំរកស៊ីទៅ ទម្រាំតែរលត់...។

**រលត់៣** *កិ.* សូន្យ, បាត់, អស់, ស្លាប់ :

- ❖ រលត់ទុក្ខ

- ចិត្តរលត់
- រលត់ស្មារតី
- រលត់កំហឹង
- រលត់កិលេស
- រលត់វិញ្ញាណ
- រលត់ខន្ធ (ស្លាប់)
- រលត់ចិត្ត (ស្លាប់) ...។

**រំលត់** ***កិ.*** ធ្វើឱ្យរលត់, ធ្វើឱ្យបាត់កម្ដៅ, ធ្វើឱ្យបាត់ក្រោធ :

- រំលត់ទុក្ខ។
- រំលត់ក្រោធ។

រំលត់រំលាយ *កិ. វិ.* ធ្វើឱ្យរលត់រលាយ :

- រំលត់រំលាយកំហឹង។

**អំពី ពី អំពី**

**ពី** ***ធ.***, ***អា. ធ.*** អំពី, ខាង, ឯ :

- ពីលើ
- ពីមុខ
- ពីស្ដាំ
- ពីឆ្វេង

❖ រួចពីដៃ

❖ ពីក្រោម

❖ មកពីផ្ទះ

❖ ពីក្រោយ

❖ ទៅពីព្រឹក

❖ មកពីណា?

❖ បានពីណាមក?

❖ សម្ដីចេញពីមាត់...។

**អំពី** ***អា. និ.*** ពី, ខាង, ឯ :

❖ អំពីខ្ញុំ

❖ អំពីអ្វី?

❖ ភ័យអំពីមរណៈ។

## អំពី ពុទ្ធដីកា សច្ចដីកា

**ពុទ្ធដីកា** *ន.* (**បា.**) ព្រះបន្ទូលព្រះពុទ្ធ, សំដៅចំពោះពុទ្ធវចនៈគឺ **បាលី** ដែលជាគោលដើមនៃព្រះពុទ្ធសាសនា :

❖ អដ្ឋកថាកែព្រះពុទ្ធដីកា។

❀ ខ្មែរប្រើក្លាយៗមកហៅថា **ពុទ្ធដីកា** ដែរគឺហៅដោយគោរពថាបញ្ជិតនិយាយស្ដីតែពាក្យពិតតាមលំអានពុទ្ធវចនៈប្រយ័ត្នមិនហ៊ានឱ្យល្អៀង :

❖ លោកគ្រូមានពុទ្ធដីកា

❖ ស្ដាប់ព្រះពុទ្ធដីកាលោក។

**សង្ឃដីកា** *ន.* (បា.) ដីការបស់សង្ឃ, ដីការបស់ភិក្ខុដែលចេញជាផ្លូវរាជការ, សំបុត្រសម្រាប់សាមណេរ ក្នុងសម័យបច្ចុប្បន្ននេះកាន់ជាសម្គាល់ខ្លួនទុកដូចជាសំបុត្រឆាយាសម្រាប់ភិក្ខុ (**ប្រើតាមសម័យនិយមនៃប្រទេស**)។

**អំពី ព្រលឹង អត្ត អាត្មា**

**ព្រលឹង** *ន.* ដំណើរជីវិត, ស្មារតី, វិញ្ញាណ, ស្រីសួស្ដី, សេចក្ដីសុខ, សេចក្ដីចម្រើន...។

- ព្រលឹងព្រលះ : ព្រលឹងធំតូច គឺស្មារតីធំតូចឬច្រើនតិច (ព. សា.)។
- បាត់ព្រលឹង : គាំងវិញ្ញាណ, ស្លន់ភាន់ភាំងគាំងបាត់សេចក្ដីដឹងជាក់, បាត់វិញ្ញាណ (ស្លាប់)។
- បាត់វិញ្ញាណ : គាំងវិញ្ញាណ, ស្លន់ភាន់ភាំងគាំងបាត់សេចក្ដីដឹងជាក់ (ស្លាប់)។
- បាត់ស្មារតី : គាំងស្មារតី, ស្លន់ភាន់ភាំងគាំងស្មារតីនឹកមិនឃើញព្រោះភ័យខ្លាច។

**អត្ត** *ន.* (បា.) ខ្លួន, ចិត្ត។

**អាត្មា** *ន.* (សំ.) ខ្លួន :

❖ រកស៊ីចិញ្ចឹមអាត្មា

❖ ខំប្រឹងយោងអាត្មា

❖ កើតមកជាមនុស្សនឹងគេដែរយោងតែអាត្មាពុំរួច។

**អាត្មា** *ន.* (សំ.) ចិត្ត :

**ពាក្យកាព្យ**

នរូអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធរតន៍

ចូលធ្វើឱ្យត្រង់ ដោយនូវបន្ទាត់ ហៅស្វែងសម្បត្តិ

យកផ្លូវនិព្វាន។ ៚

**អំពី មោទកភាព មោទនភាព**

**មោទកភាព** *ន.* ភាពឬភាវៈជាអ្នករីករាយ, ភាវៈនៃសេចក្តីត្រេកអរ, សេចក្តីអរគុណ :

❖ មានមោទកភាព។

**មោទនភាព** *ន.* ការពេញចិត្តឬការសប្បាយចិត្តចំពោះខ្លួនឯងដោយសារបានប្រព្រឹត្តអំពើអ្វីមួយ ឬក៏ការពេញចិត្តចំពោះជនណាម្នាក់ឬរបស់អ្វីមួយដែលមានការទាក់ទងនឹងខ្លួនផ្ទាល់។

❀ ការគោរពឬការវាយតម្លៃខ្ពស់ចំពោះខ្លួនផ្ទាល់។

❀ ការប្រកាន់ខ្លួនខ្ពស់ដោយសារតែ មុខតំណែង ទ្រព្យសម្បត្តិ ចំណេះដឹងខ្ពស់។

## អំពី យល់ព្រម ឯកភាព

**យល់ព្រម** *កិ.* ព្រមតាម, អនុលោមតាម, ឃើញត្រូវជាមួយ :

❖ យើងខ្ញុំយល់ព្រមតាមគាត់ហើយ។

**ឯកភាព** *ន.* ឬ *គុ.* ភាពមួយ, ភាពត្រូវគ្នា, ដែលមានបែបបទត្រូវគ្នា, ដែលមានសណ្ដាប់ធ្នាប់ត្រូវគ្នា :

❖ ស្រុកឯកភាព

❖ ប្រទេសឯកភាព។

## អំពី យស សក្តិ

**យស** *ន.* (បា.) អានុភាព, ឥស្សរភាព, បរិវារ, ទ្រព្យធន, កេរ្តិ៍ឈ្មោះល្អ, សេចក្ដីថ្កើងថ្កាន :

❖ មានយស

❖ ថ្កើងយស។

🙞 ខ្មែរច្រើនប្រើសំដៅលំដាប់ឋានន្តរសក្តិធំតូចឬអំណាចតាមមុខងារ, មុខក្រសួង :

❖ សក្តិ៩ហ៊ូពាន់ តែយសជាសេនាបតី គឺសក្តិត្រឹមតែ៩ហ៊ូពាន់ទេ ប៉ុន្តែទទួលស្ដីទីជាសេនាបតីបណ្ដោះអាសន្ន។

## ពាក្យកាព្យ

សក្តិពុំស្មើយស នាអ្នកខ្ពង់ខ្ពស់ ពុំស្មើចិត្តជា

រីអ្នកមានយស សម្បូរគ្នីគ្នា សុទ្ធសឹងមិត្តភ្វា

ជួយជាកម្លាំង។

**មួយបែបទៀតថា**

សក្តិពុំស្មើយស អ្នកមានរបស់ ពុំស្មើសក្តា

សូវបង់ធនធាន កុំខុសអាជ្ញា សូវមានរោគា

កុំឱ្យមើលងាយ។

**សក្តិ ន.** (សំ.) អំណាច, សេចក្តីអង់អាច, សេចក្តីក្លាហាន, កម្លាំង, ការព្យាយាមរឹងប៉ឹង, ការខ្លាំងពូកែ, ការជំនាញ, សេចក្តីធន់, ការប៉ិនធន់ទ្រាំ, លំពែង :

- សក្តិធំ
- សក្តិតូច
- សក្តិស្មើគ្នា
- អ្នកមានសក្តិ។

ឥស្សរិយាភរណៈដែលប៉ាក់ដោយចេសមាសឬចេសប្រាក់ជាដើមសម្រាប់ដាក់ភ្ជាប់នឹងអាវរបស់មន្ត្រីសម្គាល់ឱ្យដឹងថ្នាក់ធំតូច :

- សក្តិ១
- សក្តិ២
- ពាក់សក្តិ
- សក្តិមាស

❖ សក្តិប្រាក់។

**អំពី រលែក រំលែក**

**រលែក** *កិ.* ចែក, បែក, ញែក, ជាភាគ :

❖ ប្រមូលមនុស្សមិនឱ្យរលែកគ្នា។

ចែករលែក *កិ.* ចែកបែងឱ្យជាភាគស្មើគ្នាឬតិចច្រើនជាងគ្នា ប៉ុន្តែឱ្យបានគ្រប់គ្នា។

ដើររលែកគ្នា *កិ.* ដើរបែកទាសចេញពីគ្នា។

**រំលែក** *កិ.* ធ្វើឱ្យញែកចេញខ្លះ, បំបែកចេញខ្លះ, ធ្វើឱ្យរលស់ចេញខ្លះ យកចេញខ្លះ, ចែកឱ្យខ្លះតាមការគួរ :

❖ រំលែកម្ហូបចែកគ្នា។ (កុំច្រឡំ **រំលែក** និង **រលែក**)

**អំពី រូបិយបណ្ណ រូបិយវត្ថុ**

**រូបិយបណ្ណ** *ន.* (**បា.**) រូបិយវត្ថុជាក្រដាស, ក្រដាសជាតំណាងរូបិយវត្ថុនៃប្រទេសនីមួយៗ។

**រូបិយវត្ថុ** *ន.* (**បា.**) ប្រាក់, ក្រដាសប្រាក់សម្រាប់ចាយ (ប្រាក់បរទេស) :

❖ បើខ្វះរូបិយវត្ថុហើយនឹងធ្វើអ្វីក៏ពុំកើត។

**អំពី លទ្ធភាព សមត្ថភាព**

**លទ្ធភាព** *ន.* ភាពនៃអ្វីៗដែលបានសម្រេចហើយ។ ភាពដែលនឹងត្រូវបានត្រូវមាន, ផ្លូវឬដំណើរទំនងដែលនឹងអាចធ្វើឱ្យកើតការ, ការដែលអាចធ្វើ

ទៅបាន, ការដែលអាចប្រព្រឹត្តទៅបាន :

❖ រឿងនេះ យើងនឹងលែលករិះរកលទ្ធភាពយ៉ាងណាទាល់តែបានសម្រេចពុំខាន

❖ ខ្ញុំគ្មានលទ្ធភាពនឹងសម្រេចកិច្ចការនោះជូនអ្នកបានទេ។

**សមត្ថភាព** *ន.* ភាពនៃសេចក្ដីអាចប៉ិន, សេចក្ដីមោះមុត។

**អំពី លទ្ធិ សាសនា**

**លទ្ធិ** *ន.* (បា.) ការឃើញ, សេចក្ដីយល់ឃើញ, សេចក្ដីប្រកាន់ជឿ, ជំនឿ (យ៉ាងដូចជឿសាសនាជាដើម), ការប្រកាន់តាមយោបល់របស់ខ្លួន, ការប្រកាន់តាមទម្លាប់, ពិធី, បែបបទ, និយម :

❖ លទ្ធិពុទ្ធ

❖ លទ្ធិហោរ

❖ លទ្ធិនិគ្រន្ថ

❖ លទ្ធិព្រាហ្មណ៍

❖ មនុស្សមានលទ្ធិផ្សេងគ្នា។

**សាសនា** *ន.* (បា.) ពាក្យបណ្ដាំ, ពាក្យផ្ដាំផ្ញើ, ពាក្យប្រៀនប្រដៅ, ការប្រៀនប្រដៅ, លទ្ធិ, ពាក្យបង្គាប់, ការបង្គាប់បញ្ជោ; ដំណឹង; សំបុត្រ; ពាក្យ ប្រកាស, ការប្រកាសប្រាប់, ការជឿស្ដាប់, ការដាក់ទណ្ឌកម្ម, ការផ្ចាលទោស, ការកែសម្រួល, ការគ្រប់គ្រង, ការត្រួតត្រា :

- ❖ សាសនាព្រះពុទ្ធ
- ❖ សាសនាព្រាហ្មណ៍
- ❖ សាសនាយេស៊ូ។

**អំពី វរៈ វីរៈ**

**វរៈ** *គុ.* (**បា. សំ. វរ**) ប្រសើរ, ខ្ពង់ខ្ពស់, លើសលន់, ថ្លៃថ្លា, ជាចម្បង; ដែលគួរប្រាថ្នា, ដែលគួរចង់បាន, ដែលគួរជ្រើសយក, ដែលគួរសូម, ...។

**វរៈ** *ន.* (**បា. សំ. វរ**) ពរ ។

- វរជន : ជនប្រសើរ។
- វរនារី : ស្រ្តីល្អឆ្នើម។
- វរបិតា : បិតាប្រសើរ (បិតាក្សត្រ)។
- វរបុរស : បុរសប្រសើរ, ប្រុសថ្លៃ។
- វរមាតា : មាតាប្រសើរ (មាតាក្សត្រ)។

**វីរៈ** *គុ.* (**បា. សំ. វីរ**) ដែលខ្ជាប់ខ្ជួន, មាំមួន, រឹងប៉ឹង, អង់អាច, ក្លាហាន, ក្លៀវក្លា, មោះមុត, ខ្លាំងពូកែ, ដែលមានព្យាយាមខ្ជាប់ខ្ជួន។

**វីរៈ** *ន.* (**បា. សំ. វីរ**) អ្នកអង់អាច, អ្នកក្លៀវក្លា, អ្នកចម្បង, អ្នកប្រាជ្ញ។

- វីរជន : ជនអង់អាច, ...។
- វីរនារី : នារីអង់អាច,...។
- វីរបុរស : បុរសអង់អាច, ...។

- វីរភាព : ភាពដែលអង់អាច, ដំណើរអង់អាច។
- វីរសេនា : សេនាមោះមុត, សេនាខ្លាំងពូកែ...។

## អំពី វាសនា សំណាង

**វាសនា** *ន.* (បា. សំ.) ចរិយាឬចរិតដែលអប់រំសន្សំទុកឬកប់ទុកក្នុងចិត្ត, ចរិយាដែលថ្នឹកស៊ប់ស៊ាំជាប់ជាទម្លាប់កែប្រែឬកម្ចាត់ចោលពុំបាន, បុព្វចរិយានៃកាយប្រយោគនិងវចីប្រយោគ :

❖ មនុស្សមានវាសនាខុសគ្នា។

ពាក្យនេះខ្មែរច្រើនប្រើសំដៅសេចក្ដីថា «សំណាង, ព្រេងសំណាង, ភ័ព្វព្រេង, បុណ្យភ័ព្វ» :

❖ មានវាសនាល្អ

❖ វាសនាអាក្រក់។

**សំណាង** *ន.* អំពើដែលកសាង, ភ័ព្វព្រេង, ព្រេងពីនាយ :

❖ សំណាងល្អ

❖ សំណាងតិច

❖ សំណាងអាក្រក់។

- មានសំណាង : មានភ័ព្វព្រេងល្អ, មានបុណ្យភ័ព្វពីព្រេងនាយមក។

## អំពី វិចារណញ្ញាណ និង សម្បជញ្ញៈ

**វិចារណញ្ញាណ** *ន.* (បា.) ញាណឬប្រាជ្ញាជាគ្រឿងត្រិះរិះរាវរកហេតុផល

ឱ្យឃើញច្បាស់ឬឱ្យស្គាល់ខុសត្រូវ :

❖ បុគ្គលប្រកបដោយវិចារណញ្ញាណរមែងធ្វើការគ្រប់យ៉ាងឱ្យសម្រេចបានដោយល្អប្រពៃ។

**សតិ** *ន.* (បា.) ស្មារតី គឺសេចក្ដីនឹកឃើញ, ការរឭកបាន, ការរឭកឃើញមិនភ្លេច, ការចាំបាន, ការប្រុងប្រយ័ត្នមិនឱ្យភ្លេច; ដំណើរស្វាងរុងរឿងគំនិត :

❖ មានសតិ

❖ ភ្លាត់សតិ

❖ ដាស់សតិ។

**សម្បជញ្ញៈ** *ន.* (បា.) សេចក្ដីដឹងខ្លួន, ការមិនភ្លេចខ្លួន, ការប្រុងប្រយ័ត្នជា និច្ច; ការត្រិះរិះរំពឹងដឹងខ្លួនជាដរាប :

❖ មានសម្បជញ្ញៈ។

❀ ច្រើនប្រើជា **សតិសម្បជញ្ញៈ** ស្មារតីនិងសេចក្ដីដឹងខ្លួន :

❖ បព្វជិតគួរមានសតិសម្បជញ្ញៈជានិច្ច។

## អំពី **វិប្បដិសារៈ វិប្បដិសារី**

**វិប្បដិសារៈ** *ន.* (បា. **វិប្បដិសារ**) សេចក្ដីក្ដៅក្រហាយចិត្ត, សេចក្ដីនឹកស្ដាយក្រោយ, សេចក្ដីនឹកតូចចិត្តព្រោះដឹងខ្លួនថាខុស :

❖ មានវិប្បដិសារៈ។

❧ វិប្បដិសារកម្ម : អំពើដែលនាំឱ្យមានវិប្បដិសារៈ (អំពើអាក្រក់)។

- វិប្បដិសារចិត្ត : ចិត្តដែលមានវិប្បដិសារៈ។
- វិប្បដិសារភាព : ភាពនៃវិប្បដិសារៈ, ដំណើរនឹកស្ដាយក្រោយព្រោះដឹងខ្លួនជាខុស...។

**វិប្បដិសារី** *ន.* (បា.) អ្នកដែលមានវិប្បដិសារៈ។ បើស្ត្រីជា **វិប្បដិសារិនី**

## អំពី វេវចនសព្ទ សទិសសព្ទ

**វេវចនសព្ទ** *ន.* ពាក្យដែលប្រើផ្លាស់ប្ដូរគ្នាឬប្រើជាជំនួសគ្នាបាន គឺពាក្យដែលមានសូរសំនៀងខុសគ្នាតែមានដំណើរសេចក្ដីត្រូវគ្នាឬរលៀគ្នា, ដូចជា :

- ពេស្យា
- វេសិយា
- វេសី
- នគរសោភិនី
- លញ្ជិកា
- រូបជីវិនី
- រូបាជីវា
- រូបូបជីវិនី
- វណ្ណទាសី
- ប្រែថា «ស្រីផ្កាមាស» ដូចគ្នាយ៉ានេះជា វេវចនសព្ទ។

**សទិសសព្ទ** *ន.* សព្ទដែលមានសេចក្ដីលំគ្នា, សព្ទដែលមានសេចក្ដីស្រដៀងគ្នា :

- ➯ ឧត្ដម
- ➯ ខ្ពង់ខ្ពស់
- ➯ ថ្លៃថ្លា
- ➯ ប្រសើរ

✍ ជាសទិសសព្ទប្រើជាជំនួសគ្នាបាន (ដូចវេវចនសព្ទដែរ)។

**អំពី សង្កេត អង្កេត**

**សង្កេត** *ន.* (សំ. បា.) ការកំណត់, ការមត់គ្នា, ការណាត់គ្នា, ការប្ដេជ្ញាគ្នា, ការយល់ព្រមជាមួយ, សញ្ញា, ការពិនិត្យឱ្យឃើញច្បាស់ :

- ❖ ធ្វើតាមសង្កេត។

**សង្កេត** *កិ.* ពិនិត្យមើលឱ្យឃើញជាក់, ចំណាំមើលឱ្យឃើញជាក់, គ្នេរគ្នាន់មើលឱ្យឃើញជាក់, រំពឹងមើលឱ្យឃើញជាក់ :

- ❖ ត្រូវសង្កេតមើលសិន
- ❖ បានសង្កេតឃើញសព្វគ្រប់ហើយ។

**សូត្រពាលីពិនិត្យតាមអក្ខរប្បភេទ** :

- ❖ សូត្រធម៌សង្កេត។

✈ សង្កេតកម្ម : ការឱ្យសញ្ញា។

- សង្កេតការណ៍ : ហេតុដែលគួរសង្កេត, ហេតុនៃការពិនិត្យមើល។
- សង្កេតទាព : ដំណើរសង្កេត។
- សង្កេតលក្ខណៈ : លក្ខណៈនៃការពិនិត្យមើល។
- សង្កេតវិធី : បែបនៃការពិនិត្យមើល។

**អឡេត** *៩.* ការស៊ើបសួរបញ្ជាក់សាក្សី, ដំណើរស៊ើបសួរសង្កេតអ្នកដឹងការណ៍ពិត :

- ធ្វើអង្កេត។

**អឡេត** *ក៊ិ.* ស៊ើបសួរបញ្ជាក់សាក្សី, ស៊ើបសួរសង្កេតអ្នកដឹងការណ៍ពិត :

- ចាត់អាជ្ញាទៅអង្កេត។

**អឡេត** *គុ.* ដែលស៊ើបសួរបញ្ជាក់សាក្សី, ដែលស៊ើបសួរសង្កេតអ្នកដឹងការណ៍ពិត :

- អាជ្ញាអង្កេត។

## អំពី សិទ្ធិ អំណាច

**សិទ្ធិ** *៩.* (**សំ. បា.**) សេចក្ដីសម្រេច; សេចក្ដីសម្រេចផលឬផលសម្រេច, ការសម្រេចប្រយោជន៍, ការដាច់ស្រេច, ការសមប្រកប, ការសមតាមបំណង, សេចក្ដីសុខ, សេចក្ដីចម្រើន, សេចក្ដីសក្តិសិទ្ធិ, សេចក្ដីខ្លាំងពូកែ, សេចក្ដីសម្បូណ៌, សេចក្ដីសម្រេចតាមអំណាចច្បាប់, អំណាច, សេចក្ដីអង់អាច, មុខការដែលត្រូវសម្រេចលើខ្លួន។

**អំណាច** *ន.* អានុភាព គឺសេចក្ដីអាច, ដំណើរអង់អាច, សេចក្ដីអាចហ៊ាន, ដំណើរអាចធ្វើអ្វីៗបានតាមចិត្តឬតាមលំអានច្បាប់ :

❖ មានអំណាច

❖ អំណាចច្បាប់

❖ អំណាចរាជការ។

🙞 ដោយអំណាច *ឃ. និ.* ដោយសារ, ដោយកម្លាំង :

❖ ដោយអំណាចគុណបុណ្យ...។

🙞 តាមអំណាចចិត្ត *ឃ. និ.* តាមអំពើចិត្ត :

❖ ធ្វើតាមអំណាចចិត្តឥតក្រែងច្បាប់។

🙞 ឡើងអំណាច : ឡើងចាង, ឡើងដៃ

🙞 អស់អំណាច : អស់សេចក្ដីអាច, អស់អានុភាព...។

**អំពី សិរី សេរី**

**សិរី** *ន.* (**បា. សំ. ស្រី**) លម្អដែលគួរឱ្យស្រលាញ់, សួស្ដី, ស្រីសួស្ដី, មង្គល, ជោគ, សេចក្ដីសុខ, សេចក្ដីចម្រើន, បុណ្យ, បុណ្យភ័ព្វ, ភ័ព្វព្រេង, សំណាង ល្អ, ព្រេងសំណាង, ទ្រព្យ, ការមានបាន, លាភ, ឥស្សរភាព, តេជះ, អំណាច; រាជសក្ដិ, ទិព្យសក្ដិ, ភគវតី, លក្ស្មី...។

**សេរី** *ន.* (**បា. <សេរ** «សិទ្ធិឬអំណាចលើខ្លួន» + **ឥន៑** (បច្ច័យ) **«មាន»**, **សំ. ស្វៃរិន <ស្វៃរ + ឥន**) អ្នកដែលមានអំណាចលើខ្លួន, អត្តាធីន (ពាក្យ ផ្ទុយ **អសេរី, អនត្តាធីន, បរាធីន**), បើស្ត្រីជា **សេរិនី**។

## អំពី ស្វរ សំឡេង

**ស្វរ** *ន.* សព្ទ, សំឡេង, សំឡេងលាន់ឮ :

- ❖ ស្វរផ្គរ
- ❖ ឥតស្វរ
- ❖ ស្វរភ្លេង
- ❖ ស្វរកាំភ្លើង។

**សំឡេង** *ន.* សទ្ទជាតិដែលមកប៉ះសោតប្បសាទឱ្យឮ, ស្វរសព្ទដែលលាន់ ឮ, សម្ដីដែលលាន់ឮ :

- សំឡេងក្រអួន : សំឡេងណែនធ្ងន់រំពង។

## អំពី ស្ដេច សម្ដេច

**ស្ដេច** *ន.* ក្សត្រ, អ្នកដែលកើតក្នុងវង្សក្សត្រជាពាក្យផ្ទុយ **រាស្ត្រ។**

**សម្ដេច** *ន.* លោកអ្នកមានតេជះច្រើន, លោកអ្នកមានបុណ្យមានអំណាចធំ។

**សម្ដេច** *គុ.* ខ្ពង់ខ្ពស់ឧត្តុង្គឧត្ដម, ថ្កើងសក្ដិ ថ្កើងអំណាច, ថ្កើងថ្កាន។

**ពាក្យសម្រាប់ប្រើបន្ថែមលើព្រះនាមឬលើឋានន្តរក្សត្រ មន្ត្រីសក្តិខ្ពស់** :

- ❖ ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី...
- ❖ សម្ដេចព្រះមហាក្សត្រិយានី
- ❖ សម្ដេចព្រះឧបយុវរាជ
- ❖ សម្ដេចព្រះឧភយោរាជ

❖ សម្តេចព្រះវររាជជននី

❖ សម្តេចព្រះមហាឧបរាជ

❖ សម្តេចព្រះសង្ឃរាជ

❖ សម្តេចព្រះរៀម

❖ សម្តេចព្រះអនុជ...។

## អំពី **អគារ អាគារ**

**អគារ** *ន.* (**បា. សំ.**) មន្ទីរ, ផ្ទះ, រោង។

- អគារដ្ឋាន : ទីផ្ទះ។
- អគារស្ថាន : ទីផ្ទះ, អគារដ្ឋាន។
- អគារភូមិ : ជាន់នៃផ្ទះ, ថ្នាក់នៃផ្ទះ។
- អគារសិក្សា : មន្ទីរសម្រាប់រៀនសូត្រ, សាលារៀន...។

**អាគារ** *ន.* (**បា.**) អ្នកដែលមានផ្ទះឬអ្នកដែលមានប្រយោជន៍ដោយផ្ទះសំបែង (គ្រហស្ថ)។ *ព. ផ្ទ.* អនាគារ, អនាគារិយ, បព្វជិត។

**សំ. អាគារ** ប្រែត្រឹមតែ ថា «**ផ្ទះ**» ដូចជា **អគារ** ដែរក៏មាន។

- អាគារធម៌ : ធម៌សម្រាប់គ្រហស្ថ។
- អាគារិយធម៌ : ធម៌សម្រាប់គ្រហស្ថ, អាគារធម៌។ (*ព. ផ្ទ.* អនាគារធម៌, អនាគារិយធម៌)
- អាគារវិន័យ : វិន័យសម្រាប់គ្រហស្ថ, ច្បាប់គ្រហស្ថ។

## អំពី អចលនវត្ថុ អចលវត្ថុ

**អចលនវត្ថុ** *ន.* សូមមើលក្នុងពាក្យ **អចល** (គួរប្រើជា **អចលវត្ថុ** វិញ ព្រោះ **អចល** ជា គុណនាម, **អចលន** ជា នាម, ដែលពុំគួរផ្សំជាមួយនឹង **វត្ថុ** ជា នាម ដែរ, ឬប្រើ **អសង្ហារិមវត្ថុ** វិញក៏បាន)។

**អចលវត្ថុ** *ន.* អសង្ហារិមវត្ថុ, អចលភណ្ឌ (ខ្មែរច្រើនប្រើជា **អចលនវត្ថុ**)។

## អំពី អត្ថន័យ អត្ថរស អត្ថរូប

**អត្ថន័យ** *ន.* ការសម្គាល់នូវមតិ, ទស្សនៈនិងបញ្ហាសំខាន់ៗក្នុងអត្ថបទ។

**អត្ថរស** *ន.* ការសម្គាល់នូវរសជាតិខ្លឹមសារដែលអាចធ្វើឱ្យអត្ថបទមានលម្អ មានលក្ខណៈពីរោះជាទីចាប់ចិត្តចាប់អារម្មណ៍។

**អត្ថរូប** *ន.* ការសម្គាល់នូវសភាពរូបរាង ទម្រង់បែបបទនៃអត្ថបទដែលកើតឡើងអំពីវិធីតែងនិពន្ធដែលប្រើពាក្យសម្ដីឃ្លាប្រយោគ។

## អំពី អន្តោប្រវេសន៍ អាណិកជន

**អន្តោប្រវេសន៍** *ន.* ការចូលមកខាងក្នុង។ ការចូលមកក្នុងប្រទេសណាមួយដើម្បីតាំងលំនៅជាប្រាកដនៅទីនោះ ដោយឥតត្រឡប់ទៅកាន់ប្រទេសរបស់ខ្លួនវិញ, ដំណើរដែលជនបរទេសចូលមកតាំងលំនៅក្នុងប្រទេស :

- រឿងអន្តោប្រវេសន៍
- ការប្រិតប្រៀបខាងអន្តោប្រវេសន៍។

**អាណិកជន** *ន.* (**បា.**) ជនដែលនៅក្នុងអំណាចគេ, ជនអ្នកនៅក្រោមអំណាចនៃបុគ្គលដទៃ, ជនជាតិនានាដែលនៅអាស្រ័យប្រកបមុខរបរក្នុងប្រទេសដទៃ :

❖ កុងស៊ុលការពារអាណិកជនរបស់ខ្លួន

❖ ពួកអាណិកជនជាតិចិននៅប្រទេសកម្ពុជា។

**ពាក្យកាព្យ**

អាណិកជន ទោះបីមានធន ទ្រព្យច្រើនត្រឹមណា

មកនៅក្នុងរដ្ឋ ដទៃនានា ត្រូវស្តាប់បញ្ជា

តាមច្បាប់រដ្ឋនោះ។

**អំពី អាកប្បកិរិយា ឥរិយាបថ**

**អាកប្បកិរិយា** *ន.* អាការៈនៃរាងកាយ, ដំណើរឬលំនាំនៃរាងកាយឬក៏នៃឫកពា :

❖ មនុស្សនុះមានអាកប្បកិរិយារម្យទមល្អណាស់

❖ បព្វជិតគួរប្រើអាកប្បកិរិយាស្រគត់ស្រគំឱ្យសមតាមក្រឹត្យវិន័យ។

**ឥរិយាបថ** *ន.* ផ្លូវនៃឥរិយា, គន្លងនៃឥរិយា គឺការដើរ, ឈរ, អង្គុយ, ដេក។

**អំពី ឧទាហរណ៍ ឧបមា**

**ឧទាហរណ៍** *ន.* (**បា. ឧទាហរណ**) ការលើកឡើងឱ្យឃើញ, ការនាំមកពន្យល់ឱ្យឃើញ, ការចង្អុលឱ្យឃើញ; ពស្តុតាង, បែបយ៉ាង, តួយ៉ាង, គ្រឿងអាង, សំអាង :

❖ ពាក្យមានឧទាហរណ៍

❖ ដូចមានឧទាហរណ៍ថា...

❖ នាំឧទាហរណ៍មកសម្ដែងឱ្យឃើញច្បាស់។

**ឧបមា** *ន.* (បា.) សេចក្ដីប្រៀប, សេចក្ដីប្រៀបធៀប, ការប្រៀបប្រដូច, ការប្រដូច, ការប្រៀបផ្ទឹម, ការទាញយកដំណើរឬហេតុជាដើមចមមកប្រៀប, មកប្រដូចឱ្យងាយយល់ :

❖ មានឧបមាថា...

❖ មានឧបមាដូចជា...(ក្នុងសេចក្ដីធំ ប្រើជាគូគ្នានឹងពាក្យ **ឧបមេយ្យ**)។

**ឧបមា** *កិ.* (បា.) ប្រៀប, ប្រៀបប្រដូច :

❖ ខ្ញុំសូមឧបមាឱ្យឃើញ, ដូចជា...។

**ឧបមា** *គុ.* (បា.) ដែលប្រៀប, ដែលប្រដូច :

❖ ពាក្យ **ឧបមា** (ហៅ **ឧបមាកថា** ក៏បាន)។

## អំពី ឧបទ្ទវហេតុ ឧប្បត្តិហេតុ

**ឧបទ្ទវហេតុ** *ន.* (បា.) ហេតុនៃឧបទ្រព, ហេតុដែលនាំឱ្យកើតឧបទ្រព។

**ឧប្បត្តិហេតុ** *ន.* (បា.) ហេតុដែលបណ្ដាលឱ្យកើតឡើង, មូលហេតុ។

# គន្ថនិទ្ទេស

១- វចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ព.ស. ២៥១១ គ.ស. ១៩៦៧-៦៨, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

២- វិធីប្រែបាលី ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ពុទ្ធសករាជ ២៥៤៥

៣- វេយ្យាករណបទីប ព. ស. ២៤៩៥ គ. ស. ១៩៥២

៤- **ច័ន្ទ សំណាព្វ** (១៩៩៩) វិជ្ជមានន័យ អវិជ្ជមានន័យ និងបរិធាតុរបស់វា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៥- **ច័ន្ទ សំណាព្វ** (២០០២) គោលការណ៍នៃការបង្កើតពាក្យនិងកម្ចីពាក្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៦- **ច័ន្ទ សំណាព្វ** (២០០៣) ធាតុវេយ្យាករប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៧- **ច័ន្ទ សំណាព្វ** (២០០៦) ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទី នៃបុរេបទ **ការ** និងផ្នត់ជែក [-**អម/ណា**-] / [-**អំម/ន**-] សាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ

៨- ភាសាខ្មែរ (អគ្គទត្តោ គល់-សុភាព)

៩- កម្ពុជសុរិយា (លោក **ឈី-ឆាមតេខ** សមាជិកក្រុមអភិបាលសមាគមអ្នកនិពន្ធខ្មែរ)

១០- គតិលោកភាគទី១ (ឧកញ៉ាសុត្តន្តប្រីជាឥន្ទ)

១១- ព្រះគ្រូមុនីសោភ័ណ **សេខ-នាខ** សារញ្ញាណោ, បាលីវេយ្យាករណ៍, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៤៤ គ. ស. ២០០០

១២- ព្រះគ្រូសិរីសោភ័ណ **គិម-ត្នូ**, បទានុក្រមធម្មបទភាគទី១, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៣- ព្រះគ្រូសិរីសោភ័ណ **គិម-ត្នូ**, បទានុក្រមធម្មបទភាគទី២, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៤- ព្រះគ្រូសិរីសោភ័ណ **គិម-ត្នូ**, បទានុក្រមធម្មបទភាគទី៣, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៥- **អៀច-ភើស** ភាសាខ្មែរ

១៦- វចនានុក្រមខ្មែរ KHMER DICTIONARY ការផ្សាយបណ្ណាគារអង្គរធំ ព. ស. ២៥៥៥ គ. ស. ២០១១

១៧- វេយ្យាករណ៍សំស្រ្កឹត

១៨- សទ្ទានុក្រមពាក្យច្បាប់និងរដ្ឋបាល (អង់គ្លេស-បារាំង-ខ្មែរ)

១៩- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា

២០- ប្រស្នាកច្ចាយនូបត្ថម្ភកៈ កិតកនិទ្ទេស-ខុណាទិនិទ្ទេស, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

២១- **ហ៊ីខ-ឌីឫទ្ធិ** អត្ថាធិប្បាយវចនានុក្រមច្បាប់

២២- ឯកសារនានា ។

## ជីវប្រវត្តិ

ខ្ញុំ **ទូច-តីម៉ាស្រ៊ាង** កើតនៅឆ្នាំ១៩៧៤ នៅក្នុងភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ ជាកូនទី៥ ក្នុងចំណោមបងប្អូនប្រុសស្រី៦នាក់ ស្រី៤ ប្រុស២

ឪពុកឈ្មោះ **ទី-យ៉េន** ស្លាប់

ម្ដាយឈ្មោះ **អ៊ី-មាស** ស្លាប់

## ការសិក្សា

២០០៩ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យខេមរៈ

២០០៧ បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យបៀលប្រាយ

២០០៣ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

២០០១ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នៅពុទ្ធិកវិទ្យាល័យសម្ដេច **ជួន-ណាត**

១៩៩៦ ពុទ្ធិកបឋមសិក្សាវត្តសុន្ទរវង្ស ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ

១៩៨០ សាលាបឋមសិក្សាភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## មុខតំណែងនិងការងារ

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្រិតពាក្យនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរនៃវត្តខ្ទណ្ឌាលោម

ISBN-13 : 978-99963-705-0-2